D71459
(DC-CAM)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## បទសម្ភាសន៍ជាមួយលោកយាយ អ៊ុង ពូន អាយុ៦៤ឆ្នាំ នៅភូមិត្រពាំងធំ

## ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០០)

### សម្ភាសដោយ ផេង ពង្សរ៉ាស៊ី និង សាន់ កល្យាណ

រ៉ាស៊ី: លោកយាយឈ្មោះអី?

ពូន: អ៊ុង ពូន

រ៉ាស៊ី: លោកយាយមានស្រុកកំណើតអីនៅឯហ្នឹងរហូតតែម្តងអ្ហេសតាំងពីកើតមក?

ពូន: នៅហ្នឹងរហូត

កល្យាណ: តាំងពីជីដូនជីតាមកតែម្តងអ្ហេស?

ពូន: ចា៎

កល្យាណ: យាយបងប្អូនច្រើនដែរអ្ហេស? ប៉ុន្មាននាក់យាយ?

ពូន: ប្រុស៣

កល្យាណ: ប្រុស៣

ពូន: ស្រី៤

កល្យាណ: ស្រី៤

រ៉ាស៊ី: លោកយាយកូនទីប៉ុន្មានដែរ?

ពូន: ខ្ញុំកូនទីបី

កល្យាណ: កូនទី៣អ្ហេស? រួចអ៊ីម៉ុកគាត់កូនទីប៉ុន្មានលោកយាយ?

ពូន: កូនទី១

កល្យាណ: គាត់កូនទី១អ្ហេស? រួចបន្ទាប់មកអ្នកណាទៀត?

ពូន: បន្ទាប់មកអាតាមួយស្លាប់បាត់ អាតាមួយទៀតស្លាប់បាត់

កល្យាណ: គាត់ឈ្មោះអីដែរលោកអ៊ំ?

ពូន: បន្ទាប់អាតាម៉ុកហ្នឹងឈ្មោះតាចុក

កល្យាណ: អ៊ំចុកអ្ហេស?

ពូន: ចា៎

កល្យាណ: ហើយគាត់ស្លាប់ហើយដែរ?

ពូន: ស្លាប់ផុតពូជផុតអម្បូរណ៍ហើយ

កល្យាណ: ហើយបន្ទាប់អ៊ំចុកមកអ្នកណាគេ?

ពូនៈ ចាំ ស្លាប់ដែរ ។

កល្យាណៈ ហើយចុះបងប្អូនស្រីៗអ៊ំនោះ គាត់ឈ្មោះអីដែរ?

ពូនៈ ឈ្មោះអ៊ំគៀន ឈ្មោះអ៊ំគួប ហើយគៀន

កល្យាណៈ អ៊ំគួប អ៊ំគៀន

ពូនៈ គៀន ហើយ គេន អស់ ។

កល្យាណៈ គេន ហ្នឹងពៅគេហើយអ៊ំអ្នូស?

ពូនៈ ចា៎

កល្យាណៈ រួចពីតូចអ៊ំម៉ុកគាត់រៀននៅឯណាដែរអ៊ំ?

ពូនៈ ពីតូចនៅជាមួយយាយទូត

រ៉ាស៊ីៈ តាម៉ុកគាត់កើតឆ្នាំអីលោកយាយ?

ពូនៈ តាហ្នឹងដូចឆ្នាំអីទេ ឆ្លូវ ។

កល្យាណៈ ឆ្លូវ?

ពូនៈ ចា៎

កល្យាណៈ មកឥឡូវគាត់អាយុប៉ុន្មានហើយ?

ពូនៈ ចិតជាងអ្នូស? ចិតប៉ុន្មានទេ ។

កល្យាណៈ ចិត...ឆ្នាំខ្មែរខ្ញុំមិនសូវចេះរាប់ទេ ។ ចិតបួន ឬចិតប្រាំ អ៊ំ?

ពូនៈ ចិតប៉ុន្មានអ្នក? ខ្ញុំមិនសូវចេះទៀតណា៎ក ។

រ៉ាស៊ីៈ អត់ដឹងមួយពាន់ប្រាំបួនរយប៉ុន្មានទេយាយអ្នុស?

ពូនៈ អត់ដឹងទេ រឿងខ្ញុំអត់ចេះរលីង អត់ចេះអក្សរអីមួយទេ ។

កល្យាណៈ កើតភូមិណាអ៊ំ? ភូមិត្រពាំងធំណឹងឬក៏ភូមិប្រគាប?

ពូនៈ ប្រគាប

កល្យាណៈ ភូមិប្រគាប ឃុំត្រពាំងធំ ស្រុកត្រាំកក់?

ពូនៈ ហ្នឹងហើយ

កល្យាណៈ ហើយគាត់រៀននៅឯណា?

ពូនៈ គាត់កើតនៅភូមិប្រគាប ដល់ពេលនេះគាត់អត់មាននៅជាមួយឪខ្ញុំទេណា៎

កល្យាណៈ អ៊ីចឹង

ពូនៈ គាត់នៅជាមួយយាយ

កល្យាណៈ នៅជាមួយយាយ នៅឯណា?

ពូនៈ នៅភូមិប្រគាប

កល្យាណៈ នៅប្រគាបដែរ?

ពូនៈ ចា៎! ឪខ្ញុំចេញមកនេះ(ភូមិត្រពាំងគល់) ហើយនេះ

កល្យាណៈ អ៎ូ! ឪពុកអ៊ំចេញមកនៅភូមិនេះ?

ពូនៈ ស្រុកកំណើតប្រពន្ធគាត់ហ្នឹង យាយក្មេកគាត់នៅហ្នឹង ដល់ពេលគាត់ការហើយគាត់មកនៅនេះ ហើយអាតាហ្នឹងអត់មកទេ នៅជាមួយយាយគាត់ ។

កល្យាណៈ ហើយកាលគាត់រៀន គាត់រៀននៅឯណាយាយ?

ពូនៈ គាត់ដល់ពេលអាយុ១០ឆ្នាំគាត់ទៅរៀនរហូតទៅ

កល្យាណៈ រៀននៅឯណា?

ពូនៈ រៀននៅភ្នំពេញ

កល្យាណៈ រៀននៅភ្នំពេញ?

ពូនៈ ចា៎!

កល្យាណៈ ចុះគាត់អត់រៀននៅវត្តក្បែរភូមិហ្នឹងទេអ្ហេស?

ពូនៈ អត់ទេ

កល្យាណៈ ចុះឪពុកលោកអ៊ំ ឪពុកអ៊ំគាត់ធ្វើអីដែរ?

ពូនៈ អត់ធ្វើអីទេ អ្នកស្រែសុទ្ធ ។ គ្រាន់តែបួសរៀនបានចេះដឹងហ្នឹង ។

កល្យាណៈ គាត់បួសនៅឯណាអ៊ំ?

ពូនៈ បួសនៅយើងហ្នឹង ប៉ុន្តែគាត់ទៅរៀនភ្នំពេញ ហើយមកស្រុកវិញ ។

កល្យាណៈ អ៎ូ! គាត់ទៅបួសដល់ភ្នំពេញអ្ហេស?

ពូនៈ បួសឯនេះ ប៉ុន្តែ...

កល្យាណៈ បួសឯនេះហើយទៅបួសរៀននៅភ្នំពេញតទៀត?

ពូនៈ ហ្នឹងហើយ ហើយដល់ពេលការគាត់ការប្រពន្ធនៅនេះទៅ ។

កល្យាណៈ ចឹងឪពុកអ៊ំគាត់បួសបានដល់សង្រ្គាជដល់អីដែរ?

ពូនៈ អ៎ូ! បួសសង្រ្គាជចប់ធំអីឯណាឯណី គ្រូអាចារ្យកូនសិស្សរាប់មិនអស់ អត់ប្រយោជន៍ ។

កល្យាណៈ អីចឹង! ហើយម៉េចបានអត់ប្រយោជន៍ទៅវិញលោកអ៊ំ?

ពូនៈ ចុះបានប្រយោជន៍អី? កូនចៅជាប់គុកពិបាកវេទនាចង់ស្លាប់ ខ្ជិលណាស់ ធ្វើបុណ្យធ្វើអីទេ ខ្ញុំក៏ជាប់គុកដែរ ។

កល្យាណៈ អ៊ំជាប់ដែរ?

ពូនៈ ជាប់ ។

កល្យាណៈ ជាប់ពីអង្កាល់?

ពូន: ជាប់កាល៧៩មកវិញ ។

កល្យាណ: ៧៩មកវិញហ្នឹង?

ពូន: ចាំ!

កល្យាណ: ជាប់យូរទេអ៊ំ?

ពូន: ៤-៥ខែដែរ ល្មមតែសមមុខ ។

កល្យាណ: ជាប់នៅឯណាអ៊ំ?

ពូន: តាកែវ ។

កល្យាណ: ខេត្តតាកែវអ្ហេស?

ពូន: ចុះយើងប្អូនតាម៉ុកហើយមិនជាប់?

កល្យាណ: អ៊ូ! គេថាប្អូនត្រូវជាប់ដែរអ្ហេស?

ពូន: ហ្នឹងហើយ! ខ្ញុំដេរជ្ជិតលក់ផង មានគោមួយលក់ឲ្យគេបានបីម៉ឺនយកទៅឲ្យគេ គេឲ្យរួចមក ។

កល្យាណ: អ៊ូ! ឲ្យគេបីម៉ឺនគេឲ្យរួចខ្លួនមកវិញ?

ពូន: ហ្នឹងហើយ! គេថាខ្ញុំតាម៉ុកឲ្យលុយ បងប្អូន មិនដែលស្គាល់ទេលោកអើយ អាណិតទៅមើលដៃទៅ! ៗ! (លោកយាយលាដៃបង្ហាញ) ។

កល្យាណ: ដៃលោកយាយនឿយណាស់ ។

ពូន: នឿយតែរហូត មិនបានទេ បានខ្ញុំនឹកទៅក្តៅ អួតមានណាស់ ប៉ុន្តែខ្ញុំពិបាករហូតតាំងពីអាយុ១០ឆ្នាំ ។ មានណាស់ តាម៉ុកឲ្យលុយ មិនដែលឃើញទេ ។ ទើបតែឃើញម្តងកាលដែលគេឲ្យចេញទៅ ខ្ញុំទៅម្តងដែរ តែម្តងរហូត មិនទៅទេ ។

កល្យាណ: រួចកាលពីអាយុ១០ឆ្នាំហ្នឹងតាម៉ុកគាត់ទៅបួសរៀននៅភ្នំពេញតែម្តងអ្ហេស?

ពូន: អត់ទេ ទៅរៀន ដល់ពេលអាយុ២០ បានគាត់បួស ។

កល្យាណ: ទៅរៀនសាលាធម្មតាហ្នឹងអ្ហេស?

ពូន: រៀនមុនដំបូងសាលាធម្មតា ដល់ពេលគាត់បួសរៀនលោកណាំ ។

កល្យាណ: បួសរៀនលោកបួសវត្តណាអ៊ំ?

ពូន: វត្តស្វឹកេ អាលាំង...អុ...

កុសល: លង្កាអ្ហេស?

កល្យាណ: មហា...ស្វឹកេ?

ពូន: ដឹងវត្តមហាមន្ត្រីឬក៏លង្កាទេ ខ្ញុំមិនសូវស្គាល់ទៀតណាំ ។

កុសល: ក្បែរវិមានឯករាជ្យហ្នឹងទេដឹង?

ពូន: ហើយខ្ញុំស្គាល់? ភ្នំពេញនោះទៅវង្វេងមិនដឹងលិចកើតផង ។ វត្តមហាមន្ត្រីឬវត្តអីនោះ ។

**កុសលៈ** ប្រហែលលក្ខាហើយតាមមើល មានតែពីរហ្នឹងហើយគ្មានឯណាទៀតទេកាលហ្នឹង ។

**ពូនៈ** ហ្នឹងហើយ! ខ្ញុំវង្វេងអើយវង្វេង ទៅមិនបានទេ ។

**កល្យាណៈ** ហើយគាត់បួសបានប៉ុន្មានវស្សាដែរអ៊ំ?

**ពូនៈ** យី! បួសយូរទៀតអាតាហ្នឹងណា៎ ។

**កល្យាណៈ** យូរអ្ហេស?

**ពូនៈ** បួសយូរណាស់ណា៎! បួសយូរណាស់! បើឪខ្ញុំបួសឡើងម្ភៃ ។

**កល្យាណៈ** បួស២០វស្សា?

**ពូនៈ** អឺ! ហើយតាហ្នឹងដូចបួសយូរដែរ អត់ចាំទៀតនេះ ។

**កល្យាណៈ** គាត់រៀនចប់អីបានអីទេអ៊ំ?

**ពូនៈ** រៀនចប់បានសញ្ញាប័ត្រអីឪបួមលោកអីឯណាឯណីនោះ ។

**កល្យាណៈ** អ៊ីចឹង?

**ពូនៈ** ចា៎!

**កល្យាណៈ** ហើយបានគាត់សឹកមក?

**ពូនៈ** ចា៎! សុទ្ធតែបួសយូរ អត់ប្រយោជន៍ ។

**កល្យាណៈ** ហើយដែលគាត់សឹកមកគាត់...

**ពូនៈ** សឹកមកមិនទាន់បានកន្លះខែផងការប្រពន្ធ ។

**កល្យាណៈ** អ៊ូ! អត់ទាន់បានកន្លះខែទេ?

**ពូនៈ** ហ្នឹងហើយ! គាត់សក់មិនទាន់បានម្ដងផង ។ (គាត់ចុះទៅលើកសំណាបក្នុងស្រែ) ...ទម្រាំបានមេគោមួយអស់ចិត្តណា៎ ខ្ញុំនឹងចឹងតើ ។

**កល្យាណៈ** ហើយយកមេគោទៅដូរគេ?

**ពូនៈ** មេគោហ្នឹងដល់បានកូនមកលក់ទៅដោះគេទៀត អស់២ទៀត ។

**កល្យាណៈ** រួចកាលតាម៉ុកគាត់មកការប្រពន្ធហ្នឹងការនៅឯណា?

**ពូនៈ** ការនៅភូមិប្រគាប

**កល្យាណៈ** ប្រគាបហ្នឹង?

**ពូនៈ** ចា៎! ប្រពន្ធហ្នឹងបងប្អូនតាម៉ុកហ្នឹងជីដូនមួយ

**កល្យាណៈ** ជីដូនមួយគ្នាអ្ហេស?

**ពូនៈ** ម៉ែហើយនិងម៉ែបងប្អូនគ្នា ។

**កល្យាណៈ** កាលហ្នឹងគាត់អាយុប៉ុន្មានហើយយាយ?

ពូនៈ អ្ហឹ! កាលហ្នឹងដូចច្រើនហើយហ្ន៎ ប្រហែល២០ហើយណា៎ អ្ហេ! ២០ មានតែ៣០មានតែ អីឯណាឯណីណោះ ។

កល្យាណៈ បែបច្រើនហើយ ព្រោះបួសយូរដែរហ្ន៎អ៊ំ!

ពូនៈ ហ្នឹងហើយ! គ្រាន់តែបួសជាង១០ឆ្នាំ

វ៉ាស៊ីៈ ហើយប្រពន្ធគាត់ត្រូវបងប្អូនដែរ?

ពូនៈ បងប្អូនជីដូនមួយហ្នឹង ។

កល្យាណៈ ប្រពន្ធគាត់ឈ្មោះអីអ៊ំ?

ពូនៈ ឈ្មោះយាយ ខឹម

កល្យាណៈ យាយខឹម ស្អីខឹម?

ពូនៈ អ៊ុក

កល្យាណៈ អ៊ុក!

វ៉ាស៊ីៈ រួចគាត់មានកូនប៉ុន្មាននាក់អ៊ំ?

ពូនៈ កូន៨សុទ្ធតែស្រី អត់មានប្រុសទេ ។ កូនទើបនឹងមកថ្ងៃមុន មិនដែលឃើញទេ មិនដែលឃើញរលីង អស់រលីង ទើបនឹងមកថ្ងៃមុន ខ្ញុំជូនវាទៅដល់ភ្នំពេញ អាណិតដែរតើ ។

វ៉ាស៊ីៈ មកពីណាវិញ?

ពូនៈ មកពីណាទៅ? អីណាដូចកោះកុងអន្ទិតសុខ? (គាត់សួរអ្នកជិតខាងម្នាក់) ។

វ៉ាស៊ីៈ អន្លង់វែងអ្ហេស?

ពូនៈ មិនមែនទេ ។ អីទេ កំពង់សោមលើ អ៊ូស្រែអំបិលលើ កោះកុងលើក្រោមម៉េចវ៉ី ។

កុសលៈ អ៊ំដែលថាអ៊ំអន់ចិត្តដែលថាគេចាប់អ៊ំដែលថាអ៊ំជាប្អូនតាម៉ុក តាមពិតអ៊ំអត់ដែលទាក់ទងគាត់ប៉ុន្មានទេ មែនទេ? ហើយគេចាប់លោកអ៊ំទទេៗចឹង ហើយយ៉ាងម៉េចទៅ?

ពូនៈ ខ្ញុំខឹងចឹងតើ មិនដែលបានលុយមួយរៀល មិនដែលបានអង្ករមួយកំប៉ុងយកទៅឲ្យ នៅរស់នៅតែជាមួយគ្នា ឃើញខ្ញុំមានបន្តិចបន្តួច មានមេគោមួយពីរ មានបាយស៊ីគេថាតាម៉ុកឲ្យ

ឆ្នាំណាអ៊ំកាលហ្នឹង? ចាំទេ? ៨០?

ពូនៈ យើងមកពីរត់ ខ្ញុំ...អត់ដឹងដែរ ។ (សំឡេងអ្នកជិតខាងៈ ៨២-៨៣ហើយ) ។ ...អត់ចាំទេ ធ្វើការច្រើនពេកហើយហ្ន៎ យូរណាស់ ហើយដល់ចឹងទៀតទៅអាណិតដែរតើ ដ្បិតតែថានេះអាណិតដែរតើ ដែលយើងធ្លាប់ជាប់គុកអាណិតណាស់ណា៎ ផាប់ហើយខ្ញុំទៅ៥ខែជិតផាប់ណា៎ ពុតែមាត់ទេ ពុសួរឡានអត់ឃើញគេ អើតមើលបន្តិចបន្តួចគេដាក់ឡើងម៉្ងៃទៀត ។

កល្យាណៈ នៅគាកែវយើងហ្នឹង? ជាប់នៅគាកែវហ្នឹង?

ពូនៈ ជាប់ឯតាកែវ ។ ឲ្យតែយើងពុមាត់គេលួចអើតមើលមើល៍ ហើយចាស់ដងនឹកកូនដែរតើ ។

កល្យាណៈ គាម៉ុកកើតឆ្នាំអីអ៊ំ?

ពូនៈ ខ្ញុំថាឆ្នាំឆ្លូវហើយហ្ន៎?

កល្យាណៈ ឆ្នាំឆ្លូវឬឆ្នាំខាល?

ពូនៈ មានតែឆ្លូវមានតែអីហ្នឹង ។

វ៉ាស៊ីៈ ចុះគាត់ការហើយគាត់ទៅណាទៀតទៅអ៊ំ?

ពូនៈ កាលពេលការហើយបានតែកូន២ណា៎ កូន២កូន៣ហ្នឹងទៅណាទៀតទៅ លែងដឹងលែងឮ ខ្ញុំមិនសូវស្គាល់ប្រវត្តិទៀតណា៎ ព្រោះអីវាមិនបានជិតដិតអីចេះ កាលពីតូចមកនៅនៅជាមួយយាយ ដល់ពេលបួសរៀនទៅនៅភ្នំពេញ ហើយខ្ញុំ មើលមើល ប៉ុន្មានឆ្នាំបានដល់ខ្ញុំ ខ្ញុំទើបអាយុប៉ុន្មាន...៦៨ហ្នឹង ។

កល្យាណៈ ឆ្នាំនេះអ៊ំ៦៩អ្ហេស?

ពូនៈ បា៎!

កល្យាណៈ ហើយគាត់បងអ៊ំប៉ុន្មានឆ្នាំតាម៉ុក?

ពូនៈ បងច្រើនដែរ ជិត១០ឆ្នាំហ្ន៎ មើល៍ ឆ្លូវ...(គាត់រវល់បែរទៅនិយាយជាមួយអ្នកជួយដកសំណាប) ។

កល្យាណៈ អញ្ចឹងតាម៉ុកគាត់ពីក្មេងគាត់នៅជាមួយយាយ ហើយអ៊ំនៅជាមួយម្តាយ?

ពូនៈ ខ្ញុំនៅជាមួយម៉ែឪខ្ញុំឯនេះ រកស៊ីស្រែចម្ការអី ដាំដំណាំអីទៅណា៎

វ៉ាស៊ីៈ ហើយម៉េចបានជាតាម៉ុកទៅនៅជាមួយយាយចឹង?

ពូនៈ យាយស្រឡាញ់ចៅ

វ៉ាស៊ីៈ យាយស្រឡាញ់តាម៉ុកជាងគេ? ចឹងតាម៉ុកហ្នឹងចៅសំណព្វរបស់គាត់ហើយចឹង?

ពូនៈ អើ!

កល្យាណៈ ចឹងដល់ពេលការហើយគាត់នៅធ្វើស្រែធ្វើចម្ការអីឯហ្នឹងឬក៏គាត់ទៅឯណាអ៊ំ?

ពូនៈ ការហើយគាត់ទៅនៅជិតយាយហ្នឹងទៀតទៅ

កល្យាណៈ នៅជិតយាយអ្ហេស?

ពូនៈ អើ!

កល្យាណៈ រូបអន្លក់ដែលគាត់ទាក់ទងតស៊ូអីឯណាជាមួយគេហ្នឹង?

ពូនៈ ខ្ញុំអ្ហើយវាអត់សូវចេះអាដឹងឆ្នាំប៉ុន្មានអីប៉ុន្មានហ្នឹង ពិបាកណាស់ណា៎

កល្យាណៈ គាត់ការហើយប៉ុន្មានឆ្នាំអ៊ំ?

ពូនៈ កូនទី២ជាងហ្នឹងវា៤-៥ឆ្នាំ ជិត១០ឆ្នាំណោះហ្ន៎

............................

ពូនៈ នឹកណាស់ នឹកឡើងវង្វេងចង់ឆ្កួត ។

កល្យាណៈ អ៊ូ! ចិត្តអត់ដាច់ដែរអ៊ីហ្នឹ

ពូនៈ ចិត្តអត់ដាច់ទេ ងាប់ហើយ ខ្ញុំអាក្រក់ជាងគេណាស់ ចិត្តអត់ដាច់ អាណិតណាស់ ដូចវានៅរមិងរម៉ង់ ហើយដល់ទៅមើលឃើញអីចឹង ឃើញអត់បានមាត់រកមកវិញឡើងសន្លប់ ។

កុសលៈ នៅពេលឃើញហ្នឹងអ៊ំចង់សន្លប់?

ពូនៈ ហ្នឹងហើយ!

កុសលៈ មើលឃើញច្បាស់ទេភ្នែក?

ពូនៈ អត់ច្បាស់ទេ ព្រិលៗ ហើយគាត់អង្គុយអីចេះ (គាត់ងើបទៅធ្វើកាយវិការអង្គុយដូចឃើញក្នុងរូប) គាត់អង្គុយចឹងឃើញគួរឲ្យអនិច្ចាណាំ កាលហ្នឹងគាត់អត់ដឹងខ្ញុំទៅទេ ខ្ញុំទៅញឹកណាស់ណាំ... ខ្ញុំមើលឃើញស្រមោលៗហ្នឹង ខ្ញុំងងឹតចង់ងាប់ ងាប់ហើយ មកវិញឡើងសន្លប់មែនតើ ។

វ៉ាស៊ីៈ គាត់អង្គុយលើអីអ៊ំ?

ពូនៈ អង្គុយលើគ្រែគេបៀតបង្កួចហ្នឹង

កល្យាណៈ ហើយគាត់អត់ដឹងថាអ៊ំអើតមើលគាត់ពីក្រៅទេ?

ពូនៈ អត់ដឹងសោះ ។

កល្យាណៈ អីចឹងគេអត់ទៅប្រាប់ថាអ៊ំមកមើលអីចឹងទេអ្ហូស?

ពូនៈ អត់ទេ ចាំតែប្រាប់តើ ។

កុសលៈ ហើយអ៊ំទិញអីផ្ញើគាត់ដែរអ្ហូស?

ពូនៈ ផ្ញើ អ៊ូស្ហ៎ផ្ញើមាំណាស់ ខ្ញុំផ្ញើ អាណិត មុនដំបូងគាំងពីស្អី សាច់មាន់អាំងសាច់អី អន្សមជ្រូកអត់ដែល ទៅទទេទេ ។

កុសលៈ គាត់ចូលចិត្តញ៉ាំអី?

ពូនៈ គាត់ចូលចិត្តអន្សម ចូលចិត្តនំខ្មែរ ចូលចិត្តត្រីផ្អក់ សាច់មាន់ ត្រីអណ្តែង សាច់អន្ទង់អីគាត់អត់ហូបទេ សាច់ទាល់តែរាងអាំងៗ ។ ហើយខ្ញុំចេះតែធ្វើសម្លឲ្យគាត់ហុយៗទៅ សាច់ជ្រូកសាច់អីទៅ យើងធ្វើបង្អួយលាតៗទៅ ហើយហុយៗឲ្យគាត់ទៅណាំ ។

វ៉ាស៊ីៈ ហើយពេលដែលយកទៅគាត់អរទេ?

ពូនៈ ឃី! គេឲ្យយើងឲ្យ? ងាប់ហើយ

វ៉ាស៊ីៈ អូគេអត់ឲ្យយើងហុចឲ្យផ្ទាល់ដៃទេ?

ពូន: អ៊ូយ! ខ្ញុំខ្ជិលណាស់ បានពិបាកចិត្ត ប៉ុន្តែវាមិនអស់ចិត្ត ចេះតែអាណិត ខ្ញុំចេះតែយកទៅឲ្យទៅ បានហូបចឹងយើងបានហូបនឹកឃើញណ៎ មិនដឹងហេវអី ចេះតែយកទៅ ។ ចុះឲ្យគេអ្នកយាមយកឲ្យហ្នឹង ឆាប់ហើយ វាមិនអស់ចិត្តយើង បានប៉ុន្មានម៉ាត់ក៏យកទៅហ្ន៎ស!

កុសល: អ៊ំជឿថាគេយកទៅឲ្យដែរ?

ពូន: ថាបានមួយម៉ាត់ក៏ដោយឲ្យតែបានយកទៅហ្នឹងណ៎

កុសល: តែអ៊ំជឿថាអ្នកយាមគេយកទៅឲ្យទេ? យករបស់អ៊ំទៅឲ្យទេ?

ពូន: ឥឡូវមិនជឿក៏ខ្ញុំមិនហ៊ានថា អត់ដឹង

កល្យាណ: ចា៎! យើងអត់ឃើញ អត់ដឹង

ពូន: អឺ! យើងមិនឃើញយើងកុំនិយាយ ឲ្យគេទទួលទៅ គេយកឲ្យប៉ុន្មានក៏យើងអរទៅ ។

កល្យាណ: ហើយចុះពីក្មេងគាត់ចូលចិត្តពីសាអី?

ពូន: កាលពីក្មេងគាត់ចូលចិត្តចឹងដែរហ្នឹង សាច់អីៗគាត់មិនសូវទេ ។

កល្យាណ: គាត់ចូលចិត្តត្រីអាំងត្រីអីចឹងទៅ?

ពូន: ហ្នឹងហើយ! ចូលចិត្តត្រីក្រាញ់អាំង ត្រីរ៉ស់អាំងអីទៅ ត្រីដុតអីទៅ

កល្យាណ: ហើយគាត់ចូលចិត្តលេងអី?

ពូន: គាហ្នឹងដូចជាមិនសូវចូលចិត្តលេងអីទេ ដូចដឹង... តែរកស៊ីអីក៏មិនសូវខំដូចគេដែរណ៎ មិនសូវចេះចង់បានយកទៅទុកទេ ចូលចិត្តតែទៅដើរទៅរៀនសូត្រអីតែគាត់ៗហ្នឹងទៅ ។

កល្យាណ: គាត់ស្លូតឬកាចអ៊ំ?

ពូន: ឆ្ងល់គាហ្នឹងទៀតណ៎ ខ្ញុំរកថាកាចក៏ដូចជាមិនដឹង រកថាស្លូតក៏ដូចជាមិនដឹង ព្រោះអីវាល្បីថាគាម៉ុកសម្លាប់មនុស្សហ្ន៎ស?

កុសល: អ៊ំជឿដែរ?

ពូន: ដឹងអាម៉េចបើខ្ញុំមិនឃើញ មិនឃើញ ហើយប៉ុន្តែល្បីឈ្មោះគាម៉ុកហើយវៃចោល ប៉ុន្តែយើងមិនឃើញនឹងភ្នែក ។

កល្យាណ: ចុះអ៊ំធ្លាប់ដឹងចរិតគាត់ ថាចរិតគាត់អាចទៅអីចឹងទេ? អាចដូចគេចោទទេ?

ពូន: ត្រីមួយមិនដែលឆាប់ គិចថាឲ្យទៅចាប់ត្រី ឲ្យទៅចាប់មាន់អី អត់ទេ តាំងពីអាយុ៨ឆ្នាំទៅនោះ មិនដែលថាចាប់មាន់មួយយកមកហូប ឬក៏រកត្រីមួយយកមកឲ្យម៉ែឪទេ ពូជចឹងតែម៉ង ឪខ្ញុំអត់ទេ ឪខ្ញុំម៉ាអាយ៉ូសគាត់អត់ទេ អត់មានទេ តែកូនចៅមានវៃមាន់វៃទារវល់ស្ងួនប្រូតអីហ្នឹងអត់ហូបទៀត ។

កុសល: ចឹងគាត់បែកពីអ៊ំអាយុ៨ឆ្នាំហើយណ៎ស?

ពូន: ចា៎! យូរដែរហើយ ។

កុសលៈ ហើយអាយុប៉ុន្មានទៅបានអ៊ំជួបវិញ? ប្រហែលជាពេលការបានជួបវិញ?

ពូនៈ ជួបកាលការហ្នឹងខ្ញុំនៅតូចដែរណា៎ គាត់បងខ្ញុំជិត១០ឆ្នាំឯណោះ ចុះទីបីឯណោះ ខ្ញុំមិនសូវដឹងអីច្បាស់ណា៎ កាលការគាត់ហ្នឹងអត់ទាន់...ស្រុកយើងនៅ...ស្រុកក្រណា៎ មិនទាន់មានអាវពាក់ដងហ្នឹង នៅទេ ខ្ញុំនៅជ្រលក់ម៉ាក់ក្លឿ ជ្រលក់អី ។

កុសលៈ កាលហ្នឹងអ៊ំមានចាំថាអ៊ំចូលរួមពិធីការដែរ? នៅចាំបានទេ?

ពូនៈ អត់មានចាំទេ

កុសលៈ នៅតូចពេក?

ពូនៈ ចា៎! ប្រហែលជាង១០ឆ្នាំណា៎ស?

កល្យាណៈ គាត់ការនៅភូមិប្រគាបហ្នឹងអ៊ំអ្ហូស?

ពូនៈ ការភូមិប្រគាប

រ៉ាស៊ីៈ កាលហ្នឹងឪពុកម្ដាយនៅទាំងអស់អ៊ំអ្ហូស?

ពូនៈ នៅទាំងអស់

រ៉ាស៊ីៈ កាលហ្នឹងការប៉ុន្មានយប់ប៉ុន្មានថ្ងៃ?

ពូនៈ អ្ហ៎ស កាលហ្នឹងការពីរយប់ម៉្ងៃហ្នឹង ទំនៀមទម្លាប់គេ

កុសលៈ បីថ្ងៃតែពីរយប់?

ពូនៈ មិនទេ! ម៉្ងៃពីរយប់ ។ ដូចថាម៉ោង៥ចឹងទៅ ពេលព្រឹកម៉ោង៤ម៉ោងអីហ្នឹង ។

កល្យាណៈ ចឹងកាលការហើយបានកូន១កូន២គាត់នៅហ្នឹងដដែល តើអ៊ំអ្ហឺ?

ពូនៈ កូន២ហ្នឹង...រាងដូចដើរហើយណា៎

កល្យាណៈ គាត់ដើរចោលផ្ទះអ្ហូស?

ពូនៈ ចា៎!

កល្យាណៈ ទៅណា? គាត់ទៅណា?

ពូនៈ មិនដឹងទៅណា ដើរ បន្តិចឃើញបន្តិចអត់ទៅ

កល្យាណៈ អត់អ្នកណាដឹងថាគាត់ទៅណា ធ្វើអីទេអ៊ំ?

ពូនៈ អត់ទេ

កល្យាណៈ គាត់អត់ដែលប្រាប់នរណាទេ?

ពូនៈ រឿងផ្សេងគ្នា អត់ទេ ហើយបងប្អូនខ្ញុំនៅនេះដឹងតែពីធ្វើស្រែទៅ ចិញ្ចឹមឪហ្នឹងទៅ ។

កល្យាណៈ ចុះគាត់ខស្បាហ៍ទៅលេងឪពុកម្ដាយទេ?

ពូនៈ មិនទេ គាត់នៅនោះ(ភូមិប្រគាប) ហើយឪខ្ញុំនៅនេះ(ភូមិត្រពាំងគល់)

កល្យាណៈ តែពេលដែលគាត់ដើរចោលផ្ទះចឹងគាត់ត្រឡប់មកវិញគាត់មកសំពះឪពុកម្ដាយអីទេ?

ពូន: មកដែរហ្នឹង

កល្យាណៈ ហើយគាត់អត់ជម្រាបឪពុកម្តាយថាគាត់ធ្វើអីនៅឯណា?

ពូន: អត់ទេ!

កល្យាណៈ អ្ហូ! មិនប្រាប់តែម្តង?

ពូន: អត់ទេ!

កល្យាណៈ ហើយឪពុកម្តាយលោកអ៊ំអត់មានសួរដេញដោលគាត់ថាទៅធ្វើអីនៅឯណាអីទេ?

ពូន: កាលហ្នឹងខ្ញុំវាអត់ច្បាស់ដែរ ដឹងគាត់សួរមិនសួរអីយើងភ្លេចអស់ហើយ ។

វ៉ាស៊ី: កាលហ្នឹងគាត់ការហើយគាត់រកស៊ីអីដែរអ៊ំ?

ពូន: ការហើយដូចមកធ្វើស្រែបាន២ឆ្នាំ៣ឆ្នាំហ្នឹង ស្រែគាត់ម៉ុំនោះ (គាត់ចង្អុលទៅស្រែធំៗនៅក្បែរៗនោះ) នោះៗអាធំនោះ អាស្រែពូរៀនចែកឲ្យអាម៉ាន់អាអីហ្នឹងស្រែគាត់ហើយណ៎ ពីរដួរណ៎ ហើយអាស្រែពូលីមខាងកើតភូមិអាហ្នឹងស្រែគាត់ដែរណ៎ កាលមុនឪខ្ញុំឲ្យស្រែធំៗណាស់ ។

កុសលៈ បឹងនេះសុទ្ធតែដីស្រែអ៊ំ ឪពុកម្តាយអ៊ំហើយទាំងអស់នេះ?

ពូន: នេះមីងខ្ញុំ អានេះផ្ទះតាចុកបងខ្ញុំហ្នឹង ហើយត្រង់នោះទៀតធំខ្ញុំ ត្រង់នេះទៀតធំខ្ញុំ ហើយតាអ៊ុងៗនៅកណ្តាលនេះ...(គាត់ចង្អុលជុំវិញខ្លួននិងនិយាយពីរឿងលោកតារបស់គាត់) ។

វ៉ាស៊ី: ហើយចុះដល់គាត់ធ្វើស្រែពីរឆ្នាំហើយគាត់ទៅណាទៀត? គាត់រកស៊ីអីទៀត?

ពូន: ធ្វើស្រែបានពីរបីបួនឆ្នាំនោះ គាត់បានកូន២នោះ ។

កល្យាណៈ បានកូន២ហើយគាត់ចោលផ្ទះយូរទេអ៊ំ? ចោលផ្ទះរហូតដល់ពេលណា?

ពូន: វាអត់សូវគិតគូរអារឿងចោលមិនចោលអីៗហ្នឹងទៀតណ៎ បែបអាដែល...

កុសលៈ ចុះអ៊ំប្រាប់ថា តាម៉ុក...កាលដែលគាត់កើត កើតនៅឯនេះអ្ហែស? កើតនៅភូមិហ្នឹង?

ពូន: កើតនៅភូមិប្រគាបឯណោះ

កុសលៈ នៅប្រគាបឯណោះទេ មិនមែននៅឯនេះទេ?

ពូន: ចា៎! កូន១ហើយបានមកឯនេះ

កល្យាណៈ គាត់កូនប៉ុន្មាននាក់អ៊ំ? កូនគាត់ប៉ុន្មាននាក់? ទាំងអស់ណ៎ ។

ពូន: កូនតាម៉ុកអ្ហែស? កូន៤ ។

កល្យាណៈ ៤? ឈ្មោះអីខ្លះ?

ពូន: កូន៥នាក់ ស្លាប់មួយនៅ៤ ។ រាប់អារស់ឬអាងាប់?

កល្យាណៈ អាងាប់មិនបាច់រាប់ទេ រាប់តែអារស់ទៅ ។

ពូន: រស់នៅតែ៤ ។

កល្យាណៈ ចឹង? ឈ្មោះអីខ្លះអ៊ំ?

ពូនៈ ឈ្មោះវាអត់ប្រយោជន៍ហ្នឹង ។

កល្យាណៈ ម៉េចអត់ប្រយោជន៍?

ពូនៈ ចេះតែហៅទៅណា៎ស?

កល្យាណៈ ហៅហ្នឹងហៅអីខ្លះ?

ពូនៈ ហើយអាមុខក្មួយហ្នឹងនៅមិនដឹងអាណាអាបងអាណាអាប្អូនទៀតណា៎ ។ មីមួយនោះគេហៅអាគ្រូ ដល់ហើយមកគេហៅអាហ៊ោ ដល់ហើយមកគេហៅអាហេង ដល់ហើយគេហៅអាឆិច អស់ ។

កល្យាណៈ បងនោះឈ្មោះ...បងគេ...

ពូនៈ ឈ្មោះអាគ្រូ

កល្យាណៈ អាគ្រូ?

ពូនៈ ចា៎!

កុសលៈ ចឹងតាម៉ុកមិនមែនកើតនៅភូមិនេះទេអ៊ំ?

ពូនៈ អត់ទេ!

កុសលៈ ចុះឪពុកម្តាយអ៊ំនេះឯនេះឬអត់ទេ?

ពូនៈ ឪខ្ញុំនៅហ្នឹង

កុសលៈ ចុះអ៊ំកើតនៅឯណាដែរ?

ពូនៈ ខ្ញុំមិនដឹងកើតនៅឯហ្នឹងឬកើតនៅភូមិប្រគាបទៀត ។ ចុះបើរស់នៅមិនដឹងអីផង នៅតែខ្ញុំហ្នឹង គាត់ស្លាប់អស់ហើយ ។

កុសលៈ អ៊ំឺងឬអត់ពេលដែលតាម៉ុកទៅតស៊ូអីអត់មានដែលមកទាក់ទងប្រាប់អ៊ំសោះ?

ពូនៈ អត់ទេ! ខ្ញុំអត់ដឹងគាត់ធ្វើអីៗទេ ។

កុសលៈ តើអ៊ំអន់ចិត្តទេក្រោយមក?

ពូនៈ ចុះទៅអន់ចិត្តគាត់អី គាត់រកស៊ីផ្សេងខ្ញុំផ្សេង ។ ប៉ុន្តែ នែ៎ អាដល់ពេលដែលអីឯណាបន្តិចខ្ញុំជាប់គុក បន្តិចគាត់ជាប់គុក ហើយនិងស្អីឯណា អ្ហ៊ឺយ! ខូចមនុស្ស ខ្ញុំ ។ ហើយគេអួតថាតាម៉ុកមាន យកលុយឲ្យបងប្អូន អញអត់ដែលឃើញផង គេថាអីចឹងឺង ។

កុសលៈ ឺងត្រង់ថាអត់មានរឿងអីគេចាប់អ៊ំទេៗ?

ពូនៈ ហ្នឹងហើយ ឺង ។

កុសលៈ អ៊ំឺងអ្នកណា? ឺងតាម៉ុកឬឺងអ្នកណាទេ?

ពូនៈ ឺងតាម៉ុកក៏ឺង ឺងអ៊្ហូមិនដឹងឺងឯណាឯណីទេ ។

កល្យាណៈ ចុះកាលដែលគាត់ចោលផ្ទះបាត់នោះ ដល់ប៉ុន្មានឆ្នាំបានអីបានជួបគាត់?

ពូនៈ ទៅកាលណា?

កល្យាណៈ ដែលថាពេលដែលការហើយកូន២គាត់ចាប់ផ្ដើមដើរចោលផ្ទះណា៎អ៊ី

ពូនៈ ហើយហ្នឹងម៉េច?

កល្យាណៈ គាត់ដើរចោលផ្ទះបាត់ៗគាត់អត់មានមកលេងផ្ទះលេងអីទេអ៊ំអេ្ហស?

ពូនៈ មកដែរ ប៉ុន្តែយូរៗមកម្ដងហ្នឹង ។

កល្យាណៈ យូរៗមកម្ដងប្រហែលប៉ុន្មានខែ? ប៉ុន្មានខែមកម្ដងអ៊ំ?

ពូនៈ មួយឆ្នាំអីនោះហ្ន៎ ។

កល្យាណៈ មួយឆ្នាំអីមកម្ដង?

ពូនៈ ហ្នឹងហើយ ។ ហើយមកផ្ទះប្រពន្ធគាត់នៅឯនោះហ្ន៎ ភូមិប្រគាបនោះហ្ន៎

កល្យាណៈ ហើយមកផ្ទះអ៊ីចឹងគាត់សម្រាន្តផ្ទះប៉ុន្មានថ្ងៃអ៊ំ?

ពូនៈ មកផ្ទះឪខ្ញុំមួយភ្លែតៗហ្នឹង ផ្ទះប្រពន្ធគាត់ដឹងអី ។

កល្យាណៈ ចឹងមកសំពះឪពុកម្ដាយមួយភ្លែតទៅវិញទៅ?

ពូនៈ ហ្នឹងហើយ

កល្យាណៈ ហើយកាលហ្នឹងគាត់តស៊ូឬនៅអ៊ំ?

ពូនៈ ហ្នឹងគាត់ដើរហើយហ្នឹង ។

កល្យាណៈ គាត់ដើរហើយ?

ពូនៈ ខ្ញុំដឹងគាត់ដើរហើយ ។

កល្យាណៈ គាត់ប្រាប់អ៊ំអេ្ហស?

ពូនៈ ចុះបើបាត់! ដឹងគាត់ដើរធ្វើអី

កល្យាណៈ យកបាត់ប៉ុន្តែមិនដឹងគាត់ធ្វើអីទេ ដឹងតែគាត់បាត់ពីផ្ទះចឹងទៅ?

ពូនៈ អាណាដឹងគេធ្វើតស៊ូអី អាណាដឹងគេឥស្សរៈអី ខ្ញុំមិនសូវដឹងទៀតណា៎ មិនដឹងទេ

កល្យាណៈ ហើយចុះដល់ពេលដែលភ្នំពេញនោះគាត់មានមកភូមិវិញទេ? បែកភ្នំពេញពី៧៥ណា៎អ៊ំ

ពូនៈ ពេលបែកភ្នំពេញហ្នឹងគាត់ដើរអ្ហ៎យលែងស្គាល់ផ្ទះហើយហ្នឹង លែងស្គាល់បងប្អូនហើយ គិតតែដើរមិនដឹងស្អីឯណាឯណី ទៅរហូតណារហូតណី គាត់ដើរលែងចូលផ្ទះហើយ ។

កល្យាណៈ និយាយពីកាលជនាន់អាពតណា៎អ៊ំ

ពូនៈ ហ្នឹងហើយ

កល្យាណៈ គាត់អត់មានមកហ្នឹងវិញទេ?

ពូនៈ អត់ទេ! ដើរ

កល្យាណៈ អត់ដែលមកប្រជុំមកនិយាយអីទេ?

ពូនៈ មក មកវត្តប៉ុន្មានដងអន្ទិតសុខ? (គាត់សួរអ្នកជិតខាង)

កល្យាណៈ មកប៉ុន្មានដងអ្ហេស?

ពូនៈ (សួរអ្នកជិតខាង) មានដែលមកវត្តដែរ? -សុខៈ មកកាលណា? -កាលពឆ្នាំណោ៎-សុខៈ កាលពឆ្នាំមកដែរហ្នឹងណោ៎-មកវត្ត? -សុខៈ បាទ-ខ្ញុំអត់សូវដឹងទៀតណោ៎ ព្រោះអីខ្ញុំ...-សុខៈ គាត់ដើរតាមសហករណ៍សហអីហ្នឹងណោ៎ ។

កល្យាណៈ គាត់ចុះតាមសហករណ៍ដែរអ្ហេស?

ពូនៈ ដើរអត់មាននៅផ្ទះទេ អត់នៅកន្លែងទេ ព្រោះអីខ្ញុំវាអីចេះ បងប្អូនខ្ញុំគេសុទ្ធតែអ្នករៀនសូត្រចេះដឹងណោ៎ ហើយខ្ញុំវាអ្នកអត់ចេះ ហើយអាហ្នឹងគេ...ខ្ញុំនៅតែនឹងភូមិហ្នឹង នៅតែឯហ្នឹង ហើយខ្មុខ្ញុំនុ៎ះ! ខ្ញុំអត់ទៅណាទេ គេមកហៅខ្ញុំទៅណាគេថាសប្បាយ អត់ទៅ មិនទៅទេ ។

កល្យាណៈ អត់ទៅទេ?

ពូនៈ អត់ទៅទេ ។ ផ្ទះអញសប្បាយជាង អត់ទៅទេ ។ សួរអន្ទិតសុខមើលបើខ្ញុំដែលទៅណាអត់ទេ ។

កល្យាណៈ រួចកាលជំនាន់ពឆ្នាំហ្នឹងដែលគាត់មកគាត់អត់ចូលលេងឪពុកម្ដាយបងប្អូនអីទេ?

ពូនៈ អត់ចូលទេ

កល្យាណៈ អត់ទេ?

ពូនៈ អត់ចូលទេ បើទៅជួបបងប្អូនរឹតតែអត់ទៀត ។

កល្យាណៈ ហើយកាលហ្នឹងគាត់យកប្រពន្ធគាត់ទៅនៅជាមួយឬនៅ?

ពូនៈ កាលហ្នឹងគាត់នៅតាកែវហើយណ៎អន្ទិតសុខ?

កល្យាណៈ គាត់នៅតាកែវ?

ពូនៈ ចា៎!

កល្យាណៈ ហើយគាត់យកប្រពន្ធកូនទៅឯហ្នឹង?

ពូនៈ យកទៅ ប៉ុន្តែនៅតែប្រពន្ធទេ កូនអត់នៅចូលទេ ។

កល្យាណៈ អ្ហ៎ាក! ចឹងកូនគាត់ទៅណា?

ពូនៈ កូនគាត់ឲ្យដើរតាមកងឲ្យដើរអី?

កល្យាណៈ ទៅតាមកងចល័តអីចឹងដែរ? ទៅលើកទំនប់ជីកប្រឡាយនឹងគេដែរ?

ពូនៈ ដឹងទៅធ្វើអីអ្ហ៎ក ប៉ុន្តែអត់សូវមានកូននៅជាមួយទេ ។

កល្យាណៈ ហើយចុះកាលជំនាន់ហ្នឹងបងប្អូនអ៊ំមានបានគេឲ្យធ្វើតួនាទីអីនឹងគេដែរ?

ពូនៈ យី! គេឲ្យធ្វើសុទ្ធតែគណៈឃុំណោ៎ ផាប់ហើយ ។

កល្យាណៈ សុទ្ធតែជាគណៈឃុំ?

ពូនៈ អឺ! សុទ្ធតែប្រវត្តិល្អគេ អត់ប្រយោជន៍

កល្យាណៈ អ៊ំ ចុក ធ្វើគណៈឃុំនៅឯណា?

ពូនៈ ឃុំព្រៃកប្បាស

កល្យាណៈ ព្រៃកប្បាស?

ពូនៈ ហ្នឹងហើយ

កល្យាណៈ គណៈឃុំឬគណៈស្រុក?

ពូនៈ គណៈឃុំឬគណៈស្រុកអន្ទិតសុខ?

កល្យាណៈ ហើយចុះអ៊ំ ចំ នោះ?

ពូនៈ ពកត្របែក

កល្យាណៈ អ៊ូ! ពកត្របែកអ្ហេស?

ពូនៈ អឺ! ធ្វើទំនប់ៗ ប្តីខ្ញុំគ្មោតតាចាន អឺ! ធ្វើស្រែប្រាំង អ្ហ៊េស! ធំណាស់

កល្យាណៈ សុទ្ធតែធំៗ សុទ្ធតែគណៈឃុំ

កុសលៈ ម៉េចបានអ៊ំយល់ថាអត់ប្រយោជន៍?

ពូនៈ ចុះវាសាប់ខ្លួនបាត់អស់ហើយ ជាប់គុកទៀត ហើយប្រពន្ធកូនអីនៅវេហាម អាយុ៧០ហើយ នៅតែដើរដកដើរស្ទូងចឹងៗ

កល្យាណៈ ហើយចុះតាំងពីវៀតណាមចូលមកហូតហ្នឹងអ៊ំដែលជួបតាម៉ុកទៀតទេ?

ពូនៈ វៀតណាមចូលក្រោយនេះអ្ហ៊?

កល្យាណៈ ចា៎!

ពូនៈ ចុះខ្ញុំទៅម្តងមិនជួបនៅអន្លង់វែង?

កល្យាណៈ អ៊ូ! អ៊ំទៅជួបដល់អន្លង់វែង?

ពូនៈ ហ្នឹងហើយ

កល្យាណៈ យូរឬនៅ? អ៊ំទៅជួបគាត់យូរឬនៅ?

ពូនៈ កាលអ៊ុនគាត់ហើយណ៎ស អន្ទិតសុខណ៎ស?

កល្យាណៈ អ៊ូ! កាលសម័យអ៊ុនគាត់អ្ហេស?

ពូនៈ អឺ!

កល្យាណៈ អ្នកណាគេនាំទៅអ៊ំ?

ពូនៈ មីមួយនៅខាងលិចផ្ទះខ្ញុំឯកើតហ្ន៎! វាថាទៅលេងតាម៉ុកទៅ ហើយគេបបួលខ្ញុំអើយបបួល ខ្ញុំអត់ទៅ ហើយតាំងពេលហ្នឹងមិនដឹងម៉េចបានទៅ ឆ្ងល់ទៀតៗ

កល្យាណៈ អត់ដឹងម៉េចបានទៅទេ?

ពូនៈ អឺ! ប្រុងតែអត់ទៅ

កល្យាណៈ ចឹបានអ៊ំអត់ព្រមទៅ?

ពូនៈ ខ្ញុំខ្ជិល

កល្យាណៈ មិនមែនខឹងគាត់ទេអ្ហូស?

ពូនៈ អត់ខឹងទេ

កល្យាណៈ អត់ខឹងទេ?

ពូនៈ អត់ទេ ។ ដល់ពេលខ្ញុំទៅដល់ណា៎ ចុម! ងែងមករកអីមីចោរខ្ញុំយួន ៗ នៅខាំងទៀតណា៎ នៅថាងែងមករកអីមីខ្ញុំយួន អញពូតែងែងសាប់បាត់ហើយណា៎ ។ អូ៎ ក្បាលខ្ញុំខ្ទេចខ្ទីហើយ អង្អែល ។

កុសលៈ គាត់នឹកអ្ហូស?

ពូនៈ គាត់នឹក ខ្ទេចខ្ទីហើយអង្អែល ហើយងែងមករកអី ងែងនៅរស់... អញពូថាងែងគេធ្វើបាប ច្រើនដង សាប់អ្ហីនៅរស់ ហើយយំ ។

កល្យាណៈ អូ៎! គាត់យំ?

ពូនៈ យំ ហើយខ្ញុំថា ទៅ! ទៅផ្ទះ! អញអត់ទៅទេហង ខ្លាចជាប់គុក អញទៅមិនទាន់បានទេ ហ្នឹងចឹងតើ ងែងជាប់គុកហើយ ខ្ញុំថាគ្មានអ្នកណាជាប់គុកទេ ឥឡូវគេគ្មានឲ្យទោសពៃរ៍ទេ ទៅ! អត់ទេ អញខ្លាចជាប់គុក មិនជឿទេអញ ។ ខ្ញុំបបួលថា ទៅ! គេសប្បាយចង់សាប់ហើយ ទៅ! នៅក្នុងព្រៃ សប្បាយដែរហ្នឹងក្នុងព្រៃ ខ្ញុំថាអត់សប្បាយទេ ងែងកុំទៅ ងែងនៅនេះអញអត់ឲ្យងែងធ្វើអីទេ អត់នៅទេ បានតែ២យប់មកវិញបាត់ ២យប់ខ្ញុំមកវិញ មិនចេះនៅទេក្នុងព្រៃ ព្រៃតើ ក្នុងព្រៃមិនចេះនៅទេ ។

វ៉ាស៊ីៈ ព្រៃដែលគាត់នៅគេហៅព្រៃអី?

ពូនៈ ព្រៃអន្លង់វែងហ្ន៎?

កល្យាណៈ អន្លង់វែងអ្ហូស?

ពូនៈ មិនចេះនៅទេ ។ ងែងអត់នៅ ងែងនៅជាមួយអញហងអើយ ងែងបើអត់នៅជាមួយអញ បែកគ្នាហើយ ជួបគ្នាតែមួយសាហ្នឹងទេ គាត់ចេះនិយាយអីចឹងទៀតណា៎ ឆ្ងល់ទៀតណា៎ បើនៅជាមួយអញបានជួបគ្នាទៀត បើអត់នៅជាមួយអញបែកគ្នាហើយ ។

កល្យាណៈ ចុះកាលអ៊ំទៅជួបគាត់នៅឯនោះឃើញគាត់ស្គមឬកាចអី?

ពូនៈ មិនបាច់! ឲ្យតែឃើញបងប្អូនអ្នកភ្នំពេញទៅអ្ហ៎...ចេះតែទៅ ហើយចេះតែអាណិតគេ អ្ហីយ នឹកបងប្អូន ហើយសួរមកអ្នកស្រុកអ្នកភូមិយើងនេះ អាណានៅអាណាស្លាប់ សួរចាស់

សួរក្មេងអីធ្លាប់ស្គាល់គ្នាហ្នុង និយាយពីសួរអើយសួរ អាណានៅអាណាស្លាប់អីៗ ស្លាប់អី សួរអ្នកស្លាប់ហ្នឹងទៀតណាំ។

កល្យាណៈ ហើយគាត់ឲ្យអីមកដែរអី?

ពូនៈ កាលហ្នឹងខ្ញុំជួបឆ្អួត ថាខ្ញុំមកសុំលុយណាំ ខ្ញុំនិយាយត្រង់ណាំ គេប្រាប់ខ្ញុំថាមានលុយច្រើនណាស់បានខ្ញុំមក ខ្ញុំវាអត់ណាំ អត់ទាំងកូនខ្ញុំទៀត ខ្ញុំមកសុំលុយ-ហើយអញអ្នករកលុយក្រែងអញអ្នករត់អ្ហស? ងែងអញព្រួសួរលក់ព្រលឹត លក់រមៀត លក់ស្លឹកជ្រេស មានលុយច្រើនណាស់ អញអ្នករត់ទេ អញអត់លុយទេ-ឃី! អត់ទេឲ្យមកខ្ញុំទៅហើយ កូនខ្ញុំរៀនអត់លុយចង់ងាប់-អត់ទេ! អញអត់មានដែលកាន់លុយទេ គេទេ ហើយឥឡូវអញអាណិតងែងណាស់ហងអើយ ងែងនៅតែផ្ទះ អត់ដែលឃើញផ្សារអី អញឲ្យគេជូនទៅលេងថៃ-ខ្ញុំថាខ្ញុំអត់ទៅទេនាំតែអស់លុយ ឲ្យតែលុយមកខ្ញុំទៅផ្ទះ-អត់ឲ្យទេ អត់ឲ្យគ្រាន់តែមិនទាន់ក្ជីងងដឹកខ្ញុំទៅបាត់ ដឹកទៅថៃហ្នឹង ឲ្យខ្ញុំ៥០០ទៅថៃ។

កល្យាណៈ ៥០០បាតអីអ្ហស?

ពូនៈ ហ្នឹងហើយ

កល្យាណៈ ហើយអីជួបគាត់ដល់ហ្នុងបានតែម្ដងហ្នឹង?

ពូនៈ បានតែម្ដងហ្នឹង

កុសលៈ ហើយគាត់ឲ្យលុយអីតែ៥០០បាតហ្នឹងទេ?

ពូនៈ ហើយដល់ពេលមកវិញ ពេលមកវិញឲ្យខ្ញុំ៣០០០បាត ខ្ញុំថាយកទៅបានប៉ុន្មាន? គាត់ថាអញព្រួថាដូរ១០០០បាន៦០០០០ដែរកាលហ្នឹង ថាយកទៅធ្វើអីប៉ុណ្ណឹង មិនបានខ្ញុំលក់មេគោមួយ-ចុះងែងមកឆាប់ពេកអញអត់បានទៅសុំគេហងអើយ លុយនៅគេ។

វ៉ាស៊ីៈ នៅគេហ្នឹងអ្នកណាគេ?

ពូនៈ នៅគេអ្នកកាន់លុយ គាត់មិនមែនអ្នកកាន់លុយទេ លុយនៅគេ ខ្ញុំថាអត់ជឿ-អត់ទេអញមិនដែលមានច្រើនជាងហ្នឹងទេ សួរចុះ អញអត់កាន់លុយទេ ហ្នឹងអញអាណិតងែងអញមាន៣០០០ហ្នឹងឲ្យទាំងអស់។

វ៉ាស៊ីៈ ហើយអីជឿគាត់ថាគាត់អត់លុយចឹងទេ?

ពូនៈ ខ្ញុំអត់ជឿ បើល្បីចង់ងាប់

កល្យាណៈ ល្បីថាម៉េចអី?

ពូនៈ ល្បីអ្នកស្រុកអ្នកភូមិហ្នឹងគេទៅគេថាតាម៉ុកមានលុយហ្នឹង ហើយបានខ្ញុំទៅ ហើយគាត់ថាគាត់អត់ទេ។

កល្យាណៈ ហើយអីអត់ជឿទេ?

ពូន៖ អត់ជឿទេ

កុសល៖ ប៉ុន្តែគាត់ស្រលាញ់អ៊ំសឹងអី ហេតុអីគាត់មិនឲ្យ?

ពូន៖ អាណិតខ្ញុំនោះលោកអើយអាណិត គិតតែអង្អែលក្បាលយំ អាណិតថាខ្ញុំនេះល្ងង់ជាងគេ ក្រជាងគេ រកស៊ីចិញ្ចឹមម៉ែឪ អត់បានទៅរៀនសូត្រដឹងសប្បាយនឹងគេ ខ្ញុំចិញ្ចឹមម៉ែឪខ្ញុំតើ ម៉ែឪខ្ញុំគាត់ធ្វើបុណ្យធ្វើទាន ខែភ្ជុំគាំងពីថ្ងៃ១ រោចរហូតដល់ថ្ងៃ១ កើតមិនទាន់មកផ្ទះវិញទេ ចូលឆ្នាំ៣ថ្ងៃ៤ថ្ងៃគាត់នៅវត្តរហូត ហើយកូនសុទ្ធតែកូនប្រុស កូនស្រីតែខ្ញុំមួយនៅក្បែរគាត់ហ្នឹង ។

កុសល៖ ចុះម៉េចអ៊ំមិនទៅនៅភ្នំពេញជាមួយកូន?

ពូន៖ កូនហ្នឹង? ...អន្តុយសុំចង់ងាប់គេអត់ឲ្យខ្ញុំ ហើយយើងអត់លុយទៅនៅម៉េច អត់លុយអត់មានផ្ទះនៅណា៎ ។

កុសល៖ ចុះកូនអ៊ំ មានការមានអីប្ដនៅ?

ពូន៖ កូនខ្ញុំទៅនៅរៀន មិនទាន់មានផ្ទះមិនទាន់មានអីផង តែកូនខ្ញុំហ្នឹងអាណិតចង់ងាប់ហើយ ទៅនៅនឹងគេ អត់ផ្ទះនៅដើរដេកផ្ទះគេ ។

កុសល៖ កូនអ៊ំដែលសួរអ៊ំពីរឿងតាម៉ុកទេ?

ពូន៖ អាណឹងទៅសួរខ្ញុំចង់ងាប់

កុសល៖ បែបនឹកអ៊ំតាមមើល

កល្យាណ៖ គាត់ដែលស្គាល់មុខតាម៉ុកដែរ?

ពូន៖ អត់ទេ

កល្យាណ៖ អត់ស្គាល់ទេ ហើយគាត់ចង់ជួបចង់ស្គាល់ដែរ?

ពូន៖ ចង់ជួបណាស់ ប៉ុន្តែទៅគេអត់ឲ្យចូល

កុសល៖ កូនអ៊ំសួរអ៊ំថាម៉េចទៅពីរឿងតាម៉ុក?

ពូន៖ គ្មានសួររឿងអីផង

កុសល៖ អត់សួរថាអ៊ំណឹងម៉េច មុខមាត់រូបរាងម៉េច...

ពូន៖ សួរ ថាអ៊ំមុខអាម៉េចទៅម៉ែបើគេថាគាត់ប៉ិនដើរនយោបាយអីៗហ្នឹង នយោបាយអាម៉េចអី គាត់មុខអាម៉េចអី កើតមកអី ប៉ុន្តែខ្ញុំមិនដឹងថាម៉េចដែរ ។

កល្យាណ៖ មនុស្សគាត់ស្លូតបុកាចអ៊ំ

ពូន៖ តាហ្នឹង?

កល្យាណ៖ ចា៎!

ពូន៖ ខ្ញុំរកថាមិនឃើញទេ

កល្យាណៈ ម៉េចចឹង?

ពូនៈ ចុះបើនៅស្រុកភូមិវាដូចអត់ឃើញអី បើត្រីមិនសម្លាប់ផង ហើយដល់ពេល៣ឆ្នាំនេះគេថាសម្លាប់មនុស្សខ្ញុំវាអត់ឃើញ ។

កល្យាណៈ អ៊ំអត់បានឃើញទេ ឮតែគេថា

វ៉ាស៊ីៈ អ៊ំជឿថាបងរបស់អ៊ំ គាម៉ុកហ្នឹងសម្លាប់មនុស្សមែនទេ?

ពូនៈ ដឹងអាម៉េច ឲ្យជឿមិនជឿទាល់តែយើងឃើញពិតណាស់

វ៉ាស៊ីៈ ហើយលោកយាយដែលឃើញទេ?

ពូនៈ អត់ទេ! អត់ដែលឃើញទេ ខ្ញុំនៅតែនឹងភូមិហ្នឹង មានដែលដើរទៅណា

វ៉ាស៊ីៈ ហើយមានដែលឮសួរអ្នកស្រុកអ្នកភូមិហ្នឹង ឬក៏អ្នកសហករណ៍អីគេថាឃើញគាម៉ុកសម្លាប់មនុស្សអីទេ?

ពូនៈ (នៅស្ងៀម)

កល្យាណៈ ដែលឮគេថាគាម៉ុកឲ្យមកធ្វើនេះ គាម៉ុកឲ្យមកចាប់អ្នកនេះអី អត់ទេអ្នស?

ពូនៈ វាអត់សូវដឹងដែលឮ ព្រោះខ្ញុំ បើបានដើរតាមកងដែរស្រួល ។

កល្យាណៈ ចឹងអ៊ំអត់បានដើរតាមកងទេ នៅតែភូមិទេ?

ពូនៈ គេឲ្យនៅដាំបាយ រើសអង្ករ ចាស់ហើយ ។

កល្យាណៈ ហើយគាត់កាលហ្នឹងគាត់ដែលមកជាមួយថ្នាក់មេៗលើៗអីមកប្រជុំឯណឹងទេអ៊ំ?

ពូនៈ កន្លែងត្រពាំងធំយើងហ្នឹង អ្នាសកន្លែងត្រពាំងគល់ភូមិហ្នឹង ភូមិត្រពាំងគល់ហ្នឹងគាម៉ុកអត់ដែលមកទេ ។

កល្យាណៈ ឯណឹងមិនដែលមកទេ ចុះឯត្រពាំងធំនោះ?

ពូនៈ ត្រពាំងធំដែលមក

កល្យាណៈ មកជាមួយអ្នកណាគេខ្លះអ៊ំដឹងទេ?

ពូនៈ មិនដឹង បើខ្ញុំអត់ដែលដឹងផង ខ្ញុំនៅក្នុងភូមិ ។

កល្យាណៈ អត់ដឹងទេ? មិនដែលឮគេនិយាយគេថាអីទេ?

ពូនៈ អត់ទេ អត់ដែលឃើញ ។

កល្យាណៈ ហើយគាត់មកក៏អត់ដែលមកសួរមកលេងអីដែរ?

ពូនៈ អ្ហូយអត់ទេ អត់មកសួរមកលេងអីស្រុកភូមិទេ ។

កល្យាណៈ ហើយជំនាន់ហ្នឹងអ៊ំពីសាផ្អែតទេ?

ពូនៈ កាលហ្នឹង?

កល្យាណៈ ចាស៎!

ពូន: អាភូមិខ្ញុំហ្នឹងគេវាល់ចែកគ្នាប៉ុន្តែឆ្អែតដែរហ្នឹង

កល្យាណ: វាល់ចែកគ្នាអ្ហូស?

ពូន: បបរ

កល្យាណ: ម្នាក់បានប៉ុន្មាន?

ពូន: ហូបម៉ាសេរី

កល្យាណ: ហូបម៉ាសេរី?

ពូន: ចាំ!

កល្យាណ: វាល់ប៉ុន្តែហូបម៉ាសេរី?

ពូន: បបរ តាមរោងសហករណ៍ នុះ! ។!

កល្យាណ: អ្ហូ! បបរអ្ហូស? បបរ ប៉ុន្តែហើយហូបមួយឆ្អែតចឹងទៅ?

ពូន: អឺ! ម្ល៉ូពីរដង ហើយអាពួកធ្វើស្តូរបេះតែធ្វើទៅ បានស្តូរទៅទុកពាង នេះ (គាត់ចង្អុលទៅដើមត្នោត) ។

កល្យាណ: ត្នោតអស់ហ្នឹងអ្ហូសគេធ្វើស្តូរ?

ពូន: អឺ! ត្រង់នេះដាំដំណាំ

កល្យាណ: ហើយចុះជំនាន់ហ្នឹងគាត់អត់មានមកសួរអីថាម៉េចៗអី ជួយ ឲ្យអីៗទេ?

ពូន: ឲ្យ អាបងថ្លៃខ្ញុំជីដូនមួយនោះហៃដើរណាស់ ហៃដើរទៅតាកែវទៅអីបានប្រហុក បានចាន បានអីមក តែខ្ញុំមិនដែលទេ ។

កល្យាណ: ដើរទៅរកគាត់នៅតាកែវហ្នឹងអ្ហូស?

ពូន: ហ្នឹងហើយ!

កល្យាណ: ហើយបានមក?

ពូន: បានប្រហុកបានចានបានអីហូបគ្រប់គ្រាន់ហ្ន៎ស

កល្យាណ: បើអត់ទៅរកគាត់អត់បានទេ?

ពូន: អត់ទេ

កល្យាណ: គាត់អត់មកមើល?

ពូន: អត់ទេ

កុសល: អឺដែលទៅលេងផ្ទះគាត់នៅតាកែវទេ?

ពូន: អត់ទេ អត់ស្គាល់ទេ មិនដឹងផ្ទះហ្នឹងមុខអាម៉េចទេ

កុសល: ដែលពូគេនិយាយពីរឿងផ្ទះហ្នឹងដែរ?

ពូន: ពូថាមានផ្ទះ ហើយដូចយាយឃឹម យាយកែប យាយទែមអីហ្នឹង ប៉ិនណាស់

កល្យាណៈ គេប្រាប់ថាផ្ទះគាត់ធំឬតូច?

ពូនៈ ផ្ទះធំ ប៉ុនទៅរកប្រហុករកអីយកមកហូបចឹងដែរ

កល្យាណៈ ហើយតាំងពីគាត់ត្រូវគេចាប់មក...គេចាប់បានប៉ុន្មានខែបានអ៊ីដឹង?

ពូនៈ កាលហ្នឹងដូចឆាប់ដែរ

កល្យាណៈ អ្នកណាគេមកប្រាប់អ៊ីរឿងគាត់ត្រូវគេចាប់បានមក?

ពូនៈ ខ្ញុំឮបងប្អូនខ្ញុំនៅភ្នំពេញ

កល្យាណៈ ចឹង បងប្អូននៅភ្នំពេញគេមកប្រាប់អ្ហូស?

ពូនៈ ជីដូនមួយ គាមុតតាអីហ្នឹង ហើយបងប្អូនកូនចៅយាយ មី ហ្នឹង

កល្យាណៈ យាយ មី ហ្នឹងត្រូវម៉េចជាមួយអ៊ី?

ពូនៈ ជីដូនមួយ

កល្យាណៈ ជីដូនមួយបង្កើតអ្ហូស?

ពូនៈ ចា៎! ឪហើយនិងម៉ែបងប្អូនគ្នា ។

កល្យាណៈ អ៊ូ! ឪយាយ មី ហើយនិង...

ពូនៈ ឪខ្ញុំហើយនិងម៉ែគាត់

កល្យាណៈ អ៊ូ! ឪអ៊ីហើយនិងម៉ែគាត់ត្រូវជាបងប្អូនបង្កើត?

ពូនៈ ហ្នឹងហើយ!

កល្យាណៈ ហើយអ៊ីទៅមើលតាម៉ុកបានប៉ុន្មានដងហើយ?

ពូនៈ ខ្ញុំទៅ...មើល...ដែល អាថ្មីៗនោះ៣ដង អាក្រោយនោះ៤-៥ដងហើយ ទៅយកចំណីចំណុកអីឲ្យគាត់ ។

កល្យាណៈ អត់ដែលបានជួបគាត់ផ្ទាល់ទេអ៊ីអ្ហី?

ពូនៈ អត់ទេ

កល្យាណៈ ចឹងអ៊ីនៅតែចិត្តអត់ដាច់ចឹង? នៅតែស្រលាញ់គាត់...

ពូនៈ ចិត្តអត់ដាច់ទេ អាណិតណាស់ ពួកកាសែតមកសួរខ្ញុំ ខ្ញុំថា... មកចង់អាម៉េច ខ្ញុំថាមកចង់ឲ្យរួច កុំដាក់គាត់អីចាស់ហើយនោះ ។

 វ៉ាស៊ីៈ ពួកកាសែតសួរអ៊ីថាម៉េចទៅ?

ពូនៈ សួរចឹងដែរហ្នឹង ថាមកចង់ឲ្យរួច កុំដាក់គាត់អី ចំណាស់ហ្នឹងហើយគាត់មិនទៅតស៊ូអីទៀតទេ ហើយថាបើចង់ឲ្យរួចឲ្យយកលុយមក ថាខ្ញុំមិនដែលស្គាល់លុយទេ ។

កុសលៈ គេថាចឹង?

ពូនៈ ហ្នឹងហើយ

កល្យាណៈ អ្នកណាថាអ៊ំ?

ពូនៈ អាពួកស្អីគេទេ ខ្ញុំមិនសូវស្គាល់វាទៀតណា៎

កល្យាណៈ គេមកដល់ហ្នឹងអ្ហែស?

ពូនៈ គេមកដល់ហ្នឹងហើយខ្ញុំទៅដល់ផ្ទះគេទៀតណោះ មេធាវីអីគេនោះ

កល្យាណៈ អូមេធាវីគេថាឲ្យលុយឲ្យគេ គេជួយឲ្យរួចអ្ហែស?

ពូនៈ ខ្ញុំថាមិនដែលស្គាល់លុយទេ

កុសលៈ ចឹងខាងមេធាវីគេធ្លាប់មកហ្នឹងដែរ? ហើយនាំទៅ?

ពូនៈ មេធាវីហ្នឹងមិនមកទេ មកកូនចៅ

កុសលៈ ឈ្មោះអី បែនសុន សម័យ ហ្នឹងអ៊ំដែលស្គាល់ទេ?

ពូនៈ អត់ទេ

កុសលៈ ហ្នឹងមេធាវីគាត់ហើយ មេធាវីតាម៉ុក

ពូនៈ មិនដឹងអាម៉េច ខ្ញុំមិនសូវហ៊ានសួរទេ

កុសលៈ អ៊ំជឿថាគេចាប់គាត់មកហ្នឹងត្រូវឬខុស?

ពូនៈ យី! យើងខ្លាំងគេចោទពេញទីណា៎

កល្យាណៈ អ៊ំគិតថាគេចោទហ្នឹងពិតទេ?

ពូនៈ ចឹងបានថា ចុះបើគេថាចឹងហើយ

កុសលៈ ឥឡូវនេះគេមិនមែនចោទថាគាត់ខ្លាំងទេ គេចោទថាគាត់សម្លាប់មនុស្ស អ៊ំជឿថាអីចឹងទេ?

ពូនៈ ...(នៅស្ងៀម)

កល្យាណៈ ហើយអ៊ំចង់ឲ្យគាត់មកស្រុកមកភូមិវិញទេ?

ពូនៈ ខ្ញុំចង់ឃើញគាត់ចង់ងាប់ហើយ

កល្យាណៈ អ៊ីចឹងចង់ឲ្យគាត់មកនៅភូមិជាមួយវិញអ្ហែស?

ពូនៈ ចង់បើថារដ្ឋអំណាចអត់មានប្រកែប្រកាន់អីខ្ញុំចង់ឲ្យនៅជាមួយខ្ញុំទៀត ប៉ុន្តែថាមកពី...

កុសលៈ អ៊ំចិញ្ចឹមរស់ដែរ?

ពូនៈ ចុះគេបេះតែស្លឹងដកជួយចិញ្ចឹមគ្នាចឹងទៅ

កុសលៈ អ៊ំសុខចិត្តធ្វើការលំបាកដើម្បីចិញ្ចឹមគាត់ចឹង?

ពូនៈ ហ្នឹងហើយ! ចិញ្ចឹមគាត់ទៅ ឲ្យតែបានឃើញមុខទៅ ក្រែងស្លាប់ខានឃើញទៅ ចិតសិបជាងហើយ ខ្ញុំប៉ែតសិបដែរហើយ អង្គុយរាប់រាល់ថ្ងៃ នឹកណាស់ណា៎ ខ្ញុំនឹកគាត់ណាស់ នឹកណាស់ នឹកឡើងវង្វេងៗ

កុសលៈ អ៊ំមានរូបថតទេ រូបថតគាត់នៅពីក្មេងអី

ពូន: តាហ្នឹង? អត់ដែលមានទេ

រ៉ាស៊ី: កាលគាត់បួសគាត់អីគាត់មានថតទេ?

ពូន: អីមាន ប៉ុន្តែមិនដឹងឯណាអស់ទៅ អាពេលយើង...អា៧៩នេះ ឯណាអស់ទៅ ។

កុសល: ចឹងមកទល់សព្វថ្ងៃអត់មានសល់រូបថតគាត់មួយសន្លឹកក៏អត់មានដែរ?

ពូន: អត់ទេ

កុសល: អ៊ំជឿថាតាម៉ុកព្រមមកនៅជាមួយអ៊ំដែរ?

ពូន: ដឹងអី ទៅនៅយូរៗស្រងេះស្រងោចដឹងពិបាកប្រហែល មិនស្រួលមករកបងប្អូនដែរមិនដឹង ដល់ពេលធ្លាក់ខ្លួនរកបងប្អូន អាណឹងខ្ញុំថាស្មានទេណ៎ា ។

កល្យាណ: ចុះកាលមុនៗនោះគាត់អត់មាននឹកពោលចង់មកនៅជាមួយអ៊ំវិញទេអ្ហូស?

ពូន: កាលណាហ្នឹង?

កល្យាណ: កាលមុនអ៊ំធ្លាប់ទៅជួបអ៊ំនៅអន្លង់វែងនៅអីនោះ

ពូន: ជួបម្ដងហ្នឹង?

កល្យាណ: ច៎ា!

ពូន: ខ្ញុំបបួលគាត់ថាអញមិនទៅទេហង ខ្លាចជាប់គុក

កុសល: ឥឡូវអ៊ំនៅមានសង្ឃឹមថាថ្ងៃណាមួយគេដោះលែងគាត់ទេ?

ពូន: ខ្ញុំដែលតាមគេនិយាយប្រាប់ខ្ញុំ អ្នកភ្នំពេញអ្នកអីមកណឹង នយោបាយគេថាលែង ហើយក្នុងចិត្តខ្ញុំ ខ្ញុំថាក្រែងលោលែងមិនទាន់ងាប់ទេដឹង គាត់មិនសប្បាយចិត្តទេ មិនអីចឹងអ្ហូស?

កុសល: ថាពេលណាបានគេលែង?

ពូន: ដឹងអី មុននឹងលែងក្រែងងាប់ដឹង មនុស្សយើងចំណាស់ៗនេះហើយដឹងហើយ ទម្រាំគោក្របីជ្រូកមាន់អីតែនៅចឹងខ្ជិលដែរហ្នឹង បានលែងមើលហិចឥឡូវហ្នឹង ។

កល្យាណ: អ៊ំចង់ឲ្យគេលែងគាត់ដែរ?

ពូន: ចង់ណាស់

រ៉ាស៊ី: ចឹងរាល់ថ្ងៃអ៊ំចាត់ទុកគាត់ជាបងប្រុសឬជាខ្មាំង?

ពូន: ឥឡូវហ្នឹងខ្ញុំនៅតែចាត់ទុកថាបងប្អូនណឹង នៅតែបងខ្ញុំតែចឹង អាក្រក់ល្អក៏នៅតែបងដែរ បើក្រមានអីក៏ចិញ្ចឹមគ្នាទៅ ។

កុសល: ចុះបើសិនជាគេថា គេរកទៅឃើញថាគាត់មានកំហុស គាត់ខ្មាំងមែន គាត់សម្លាប់គេឧបមាទេណ៎ាអ៊ំ អ៊ំនឹងគាត់ឬក៏អ៊ំនៅចាត់ទុកគាត់ជាបងដដែល?

ពូន: ទុកជាគេធ្វើម៉េចក៏ខ្ញុំនៅតែថាបងដែរ ព្រោះអីយើង...បើ...ភាគច្រើនគេថាខ្មាំងយើងធ្វើម៉េចឈ្នះគេ ងាប់ហើយ ។

កុសល: ចុះក្នុងចិត្តអ៊ំ?

ពូន: ក្នុងចិត្តខ្ញុំនៅតែអាណិតចឹង ខ្មាំងក៏នៅតែបង ស្លាប់នៅឯណាក៏នៅតែនឹកឃើញបង ធ្វើបុណ្យធ្វើទានអីវេរឲ្យណឹងទៀតហើយ អត់ភ្លេចទេ ម៉ែឪខ្ញុំងាប់មិនដឹងនៅឯណាខ្ញុំនៅអាណិត បងប្អូនខ្ញុំអ្នកងាប់ៗហ្នឹងខ្ញុំអាណិត គ្រាន់តែបងខ្ញុំងាប់ពីរនាក់ហ្នឹងណា៎ គ្រាន់តែក្មួយខ្ញុំមកខ្ញុំនឹកណា៎ នឹកដល់បងខ្ញុំណា៎ ទម្រាំដល់ជាប់គុកចឹងទៀត ងាប់ហើយ ខ្ញុំអាណិត។

កល្យាណ: ចុះឧបមាអ៊ំណា៎ ឧបមាថាបើគាត់ធ្វើខុសមែនអ៊ំលើកលែងទោសឲ្យគាត់ទេ?

ពូន: អាណឹងដឹងម៉េចទៀតណា៎ លើកលែង...បើលើកលែងតែយើងក៏មិនរួច។

កល្យាណ: ទេ សម្រាប់ចិត្តអ៊ំណា៎ ថាគាត់មិនរួច គេឃុំគាត់ តែសម្រាប់ចិត្តអ៊ំណា៎អ៊ំលើកលែងទោសឲ្យគាត់ទេ?

ពូន: ណឹងទាល់តែភាគច្រើនដែរ តែយើងថាទៅអាណឹងក៏មិនដឹងហ៊ានថាដែរ ខ្ញុំមិនហ៊ានថាទេ។

កុសល: សួរសំណួរផ្ទាល់ខ្លួនមួយណា៎អ៊ំ ឥឡូវឧបមាថាគេ...ចិត្តអ៊ំធម្មតាបងប្អូនចេះតែចង់ឲ្យគាត់រួចវិញហើយ ប៉ុន្តែស្រាប់តែគេថាគេមានភ័ស្តុតាងថាតាម៉ុកធ្លាប់បានសម្លាប់មនុស្សមែន ញាតិមិត្តខាងគេអ្នកដែលបាត់បង់ជីវិតគេខឹងសម្បារចង់ឲ្យកាត់ទោសអីចឹងណា៎អ៊ំណា៎ ឧបមាទេណា៎អ៊ំយល់ថាតើម៉េចទៅយុត្តិធម៌?

ពូន: មិនដឹងទេ ខ្ញុំមិនចេះដែរ ខ្ញុំមិនដឹងចេះរៀនសូត្រផងហ្នឹង

កុសល: ចុះអ៊ំគិតថាធ្វើម៉េច...បើឧបមាថាឥឡូវអ៊ំចង់បានបងមកវិញ តែគេថាអ្ហូបងអ៊ំធ្វើខុសសម្លាប់បងប្អូនខ្ញុំ ឧបមាទេណា៎ ហើយអ៊ំគិតម៉េចទៅចឹង?

ពូន: (នៅស្ងៀម)

កល្យាណ: អ៊ំគិតម៉េចដើម្បីជួយគាត់តាមចិត្តដែលអ៊ំថាគាត់អត់ខុសនោះ?

ពូន: ខ្ញុំ...ចិត្តខ្ញុំអ្ហូស ចង់បានមានយោបល់ជួយគាត់ឲ្យបានភាគច្រើន អាហ្នឹងខ្ញុំ...អ្ហូយអរងាប់ហើយ ឲ្យបានគាត់រួចវិញមក ការកំហុសវាច្រើនមិនដឹងខ្លួនទេ ទាល់តែខុសហើយបានរកត្រូវឃើញ ហើយបើប្រជាជនយើងនៅមានកំហឹងឈឺចាប់តទៅទៀត ឃើញគាត់ចេះតែខ្លាំងក្តៅឡើង អាណឹងមិនរួចខ្លួននឹងគេសងសឹកវិញទេ បានខ្ញុំនឹកឃើញថា បើរស់ក៏នៅតែអាណិតទៅ បើស្លាប់ក៏នៅតែអាណិតទៅ បើបងប្អូនប្រជាជនស្រុកភូមិគេលើកលែងអារឿងចាស់អាហ្នឹងវាមានហើយស្រុកខ្មែរ កាលណាដូចកាលណាដែរ បើគេនៅតែឃើញមុខគេនៅតែខឹង យើស! ឪអញងាប់ ប្តីអញងាប់ អាណឹងអត់រួចខ្លួនទេ ងាប់ហើយ ហើយបើគេឈប់អាណឹងរួចខ្លួនទៅ ហើយរឿងមនុស្សចិត្តមនុស្សណា៎ កាលណាគេល្អជាមួយយើងអាណឹងគេអត់ឈឺចាប់ទេណា៎ ចុះថ្ងៃណាមួយគេរាងអន់ចិត្ត មានប៉ះពាល់ យើងនិយាយស្តី

ប៉ះពាល់ទៅលើគេ អាណឹងនឹកឃើញអស់ អាណឹងមានការធ្វើហើយ ចឹងណា៎មនុស្សឥឡូវ បើមិនអីចឹងមិនស្លាប់រាល់ថ្ងៃទេ ។

កុសលៈ ចុះបើអ៊ីយកមក អ៊ីបានគាត់មកនៅជាមួយអ៊ី បានគេដោះលែងអីចឹងណា៎ មកនៅជាមួយអ៊ី អ៊ីមិនខ្លាចគេសងសឹកចំពោះគាត់ទេ?

ពូនៈ ចុះខ្ញុំកាលណាដែលបានមកទៅហើយក៏មិនដឹងធ្វើម៉េច ស្លាប់រស់អីជាមួយគ្នាទៅ អាយុប៉ុនៗ ណោះហើយទៅខ្លាចអីស្លាប់ ចៀសរួច? មិនអីចឹង? អាណឹងចឹងហើយ ផ្តាច់ប្តូរចឹងហើយ ។

កុសលៈ ចុះអ៊ីចង់ឲ្យ អ៊ី...ពាក្យថាតុលាការណាអ៊ី កាត់ទោស១ តាមពិតពាក្យថាកាត់ទោសមិនមែន មានន័យថាជាប់ទោសតែម្តងទេណា៎ កាត់ទោសមានន័យថាគេរកឃើញសឃើញខ្មៅ ខ្ញុំបាន ស្តាប់អ៊ីប្រធានភូមិពួកម៉ាកគាត់នោះណា៎ អ៊ីប្រធានភូមិគាត់ថាតាមពិតអ្នកខាងក្រោម១ទេ ដែលសម្លាប់មនុស្ស តាម៉ុកអត់បានដឹងអីទេ គាត់ថាចឹងណា៎ ហើយដល់ឥឡូវស្រាប់តែគេ ចោទគាត់ថាគាត់បានប្រព្រឹត្តអំពើសម្លាប់មនុស្សអីចឹងណា៎អ៊ី ហើយអ៊ីចង់ឲ្យមានតុលាការ មួយឲ្យតាម៉ុកគាត់ឡើងការពារខ្លួនគាត់ថាន៎ែ ខ្ញុំមិនបានធ្វើអីចេះ ខ្ញុំបានធ្វើអីចុះ អ៊ីចង់ឲ្យ មានចឹងទេ? ពីព្រោះគេចេះតែចោទយើងខុសម៉េចនឹងកើត យើងចង់បានដឹងសខ្មៅណា៎ អ៊ីចង់ឲ្យមានទេ?

ពូនៈ ខ្ញុំរាល់ថ្ងៃណឹងចង់ឲ្យមានការពិត ចង់ឲ្យមានការពិតចឹងដែរ បើកាលណាគេឃើញយើងជាក់ ស្តែង ដូចគេថាសម្លាប់មនុស្សចឹងណា៎ បើគេឃើញគាត់សម្លាប់ហើយគាត់បែរជាកែខ្លួនថា គាត់អត់សម្លាប់វិញអាណឹងក៏អត់យុត្តិធម៌ដែរ ខ្ញុំចង់រកតែការពិតទេ ហ្នឹងហើយ ។

កល្យាណៈ ចុះបើគេថាគាត់មិនបានសម្លាប់ទេ តែគាត់បានបញ្ជាឲ្យគេសម្លាប់វិញនោះ?

ពូនៈ អាហ្នឹងមិនដឹងម៉េចដែរ ខ្ញុំអត់ឃើញ

កុសលៈ តែលោកអ៊ីចង់បានការពិត?

ពូនៈ ខ្ញុំចង់បានតែការពិត

កុសលៈ អ៊ីយល់ថាធ្វើម៉េចបានការពិតទៅ?

ពូនៈ អត់ដឹងដែរហ្នឹង ខ្ញុំចង់បានតែពិតចឹង

កុសលៈ តុលាការអាចជួយរកការពិតបានទេ?

ពូនៈ ដឹងអាម៉េច ខ្ញុំម៉េចដឹង

កុសលៈ អ៊ីអត់ដឹងព្រោះវាជ្រៅពេក?

ពូនៈ ហ្នឹងហើយ អ្នូយមុនដំបូងសម្មុតខ្ញុំសុទ្ធតែមកចង់ម៉េច? ខ្ញុំថាចង់ជួប ចង់ជួបសុំសំបុត្រ ទៀ បាញ់ មក អនុញ្ញាតពី ទៀ បាញ់ មក ។ ស្លាប់ហើយគ្រាន់តែកន្លែងយាមមាត់ទ្វារ

ដូចខ្ញុំណើងស្អីទៅហើយ ចុះទម្រាំដល់ខ្ញុំទៅជួប ទៀ បាញ់ ខ្ញុំមិនស្រមើលទៅហើយ ។ ចង់ជួបចង់ផាប់ ទៅមិនដែលបានជួបទេ កាលហ្នឹងទិញអីៗទៅច្រើនណាស់ ។

**វ៉ាស៊ីៈ** អ៊ំបានឃើញដែរតើអ្ហី?

**ពូនៈ** អត់ទេ កាលហ្នឹងអត់មានបានឃើញ ថ្ងៃហ្នឹងអត់មានបានឃើញទេ ។

**វ៉ាស៊ីៈ** អ៊ូ៎! ទៅថ្ងៃមុនហ្នឹងអត់បានឃើញទៀត?

**ពូនៈ** រាប់អាដែល…អាហ្នឹងទៅទីពីរណាំ៎ កាលហ្នឹងគេថាទៅៗបានជួប ខ្ញុំខំទិញអស់ច្រើនណាស់ ។

**ចប់**

# បទសម្ភាសន៍ជាមួយលោកយាយ គល់ មី អាយុ៧០ឆ្នាំ នៅភូមិត្រពាំងធំ
## ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០០)

មី: មិនដឹងឆ្នាំប៉ុន្មានៗ ប៉ុន្តែគិតកាលគាត់នៅ...

កុសលៈ កាលគាត់រៀន គាត់រៀននៅសាលានេះ? (ចង្អុលទៅសាលាត្រពាំងធំ)

មី: ហ្នឹងហើយ ។

កុសលៈ រៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

មី: រៀននេះពីដើមក្តារលីតែក្តារវែងៗ ក្តារឈើចឹងណា៎ រៀនជំនាន់ហ្នឹង ។ ហើយដល់ហើយ ឪពុកយក ទៅនៅមហាមន្ត្រី រៀននៅឯនោះតែម្តង ។

កុសលៈ រៀននៅឯនេះប៉ុន្មានឆ្នាំ?

មី: រៀនបានតែ១ឆ្នាំ ។

កុសលៈ ១ឆ្នាំ ថ្នាក់ទី១២?

មី: ហ្នឹងហើយ! អ អា ន មោ ហ្នឹងណា៎!

កុសលៈ អ៊ូ! អាយុ២-៣ឆ្នាំ? ទេ មិនមែនទេ ៤-៥ឆ្នាំ?

មី: ហ្នឹងហើយ! ហើយ...

វ៉ាស៊ីៈ កាលហ្នឹងគាត់ឈ្មោះអីយាយ?

មី: ឈ្មោះ ជឿន

វ៉ាស៊ីៈ ត្រកូលអី?

មី: អ៊ុង ជឿន

វ៉ាស៊ីៈ អ៊ុង ជឿន?

មី: ចា៎!

វ៉ាស៊ីៈ ចុះឪពុកគាត់ឈ្មោះអី?

មី: ព្រាក

វ៉ាស៊ីៈ ព្រាក?

មី: តាព្រាក

វ៉ាស៊ីៈ ត្រកូលគាត់អី?

មី: ឪពុកតាព្រាក តាអ៊ុងហ្នឹង ។

វ៉ាស៊ីៈ អ៊ូ! ចឹងអ៊ូស? អ៊ុង ព្រាក អ៊ូស?

មី: អើ!

កុសលៈ អូ៎! ចឹងគាត់យកឈ្មោះជីតាមកធ្វើត្រកូល?

មីៈ ហ្នឹងហើយ!

រ៉ាស៊ីៈ ចុះម្ដាយគាត់?

មីៈ ម្ដាយ ទូច សុច

រ៉ាស៊ីៈ ទូច សុច! ហើយដល់ពេលរៀននៅភ្នំពេញទៅម៉េចទៀតទៅយាយ?

មីៈ រៀនហើយដល់គាត់ប្រឡងធ្លាក់ទៅគាត់ទៅបួសណា៎! បួសហើយគាត់រៀនបានសញ្ញាប័ត្រព្រះត្រៃបិដក ។

រ៉ាស៊ីៈ មានដឹងឆ្នាំទេយាយ? ពេលដែលគាត់ប្រឡងធ្លាក់ហ្នឹងឆ្នាំណាទៅ?

មីៈ វាអត់ដឹង ។ ដឹងតែកំណើតគាត់ឆ្នាំខាល ។ ហើយមិនដឹងឆ្នាំប៉ុន្មានៗ យាយមិនដែលរៀនត្រង់ហ្នឹងបានមិនដឹងឆ្នាំប៉ុន្មានៗទេ ។

កល្យាណៈ គាត់បួសបានប៉ុន្មានឆ្នាំដែរយាយ?

មីៈ យី! បួសយូរណាស់ ។

កល្យាណៈ បួសនេនឬបួសភិក្ខុ?

មីៈ បួសនេនហើយបួសភិក្ខុទៀត ។ មនុស្សប្រឡងបានសញ្ញាប័ត្រព្រះត្រៃបិដកទៅហើយបួសតិចម៉េច? ខ្ទង់១០ឆ្នាំ ។

កុសលៈ ចប់ព្រះត្រៃបិដក?

មីៈ ហ្នឹងហើយ! រូបទេសន៍មើល មួយយប់អត់ចប់ទេ ។

កុសលៈពូកែណាស់ចឹង! ចឹងរៀនសាលាអត់ពូកែទេ តែពូកែខាងសាសនាវិញ?

មីៈ គាត់ប្រឡងបាក់ (Bacc) ធ្លាក់ ។

រ៉ាស៊ីៈ ប្រឡងថ្នាក់ទី១ធ្លាក់អ៊ូ៎ស? មិនមែនប្រឡងឌីប្លូមទេចឹង?

មីៈ ទេ! ឌីប្លូមជាប់ ។

រ៉ាស៊ីៈ ឌីប្លូមជាប់?

មីៈ ចាំមើលណា៎! និយាយៗត្រង់ចុះ ។ បង មូល បងយាយហ្នឹងប្រឡងជាប់ដល់បាក់ឌុបជាប់និស្សិតស្រុកបារាំង ហើយគាត់អត់ជាប់គាត់បួសរៀនយកសញ្ញាប័ត្រខាងព្រះត្រៃបិដក

កុសលៈ លោកយាយតាមមើលបែបរៀនពូកែណាស់ ។

មីៈ តាម៉ុកហ្នឹង?

កុសលៈ ទេ! លោកយាយណា៎!

មីៈ យាយអត់រៀនផង ម៉ែអត់ឲ្យរៀន រៀនតែកូនប្រុស២ ។ ម៉ែអត់ឲ្យរៀនទេ គាត់ថាកូនស្រីរៀននាំផ្ញើសំបុត្រឲ្យសង្សារ ។ ចាស់ពីដើមឆោតណាស់ ។ ហើយដល់កូនប្រុសណា៎ សុទ្ធតែ

ស្រុកបារាំងទាំងអស់ អត់មានឲ្យនៅខ្សោយទេ ។ បង មូល ហ្នឹងផ្កាយបីខាងកប៉ាល់ហោះ នៅពោធិចិនតុងណា៎! ។

កុសលៈ បងលោកយាយហ្នឹង?

មីៈ បងបង្កើតណា៎! សុទ្ធតែស្រុកបារាំង ។ ទៅមុនដំបូងពាក់សក្តិ៣ ។ ទៅរៀនបាន៦ឆ្នាំត្រឡប់មកវិញ ដល់កាល...ហ្នឹងចូលមកថាមកយកម៉ែឪជិះកប៉ាល់ហោះឡើងជាមួយកូនអាគ្និន កូនគាក្បាត់អីនេះ ។ វាបាញ់ធ្លាក់ទៅហ្នឹង ហើយស្លាប់ទៅណា៎! គាត់មកយកម៉ែឪរត់ទៅនៅបារាំងណា៎ ។ ហើយស្លាប់ទៅនៅតែកូនហ្នឹង ។ កូន៦នាក់ប្រុសទាំងអស់ ។

រ៉ាស៊ីៈ ចឹងបងប្អូនបង្កើតលោកយាយរៀនជាមួយតាម៉ុកហ្នឹង?

មីៈ គ្មានទេ! គ្រាន់តែស្រុកនៅជុំគ្នា ។ ដូចថាសាលាត្រពាំងធំចឹងតាម៉ុកគាត់នៅខាងប្រគាបចឹងទៅណា៎ ហើយនេះត្រពាំងធំចឹងរៀនទៅ បង មូល គាត់ប្រឡងជាប់ទៅចេះតែទៅៗ ហើយតាម៉ុកធ្លាក់គាត់បួសទៅ គាត់ទៅនៅមហាមន្ត្រីដែរ ។

រ៉ាស៊ីៈ ហេតុអីបានជាគាត់ចូលបួសលោកយាយ? គាត់មិនព្រមខំរៀនទៀត?

មីៈ គាត់ប្រឡងធ្លាក់ ។ ចុះបើឪពុកនោះមិនសូវគិតគូរប៉ុន្មាន បើគាត់បង្រៀនលោក សឹកទៅគាត់នៅបង្រៀនលោក ។

រ៉ាស៊ីៈ អូ៎! សង្ស័យឪពុកប្រាប់ផងក៏មិនដឹង ថាឥឡូវអ្ហែងត្រូវចូលរៀនវត្តអីៗចឹងអ្ហែស?

មីៈ ស្រឡាញ់បួសណា៎!

រ៉ាស៊ីៈ អូ៎! ស្រឡាញ់បួសជាងអ្ហ៎ស? គាត់ចូលចិត្តរឿងសាសនាចឹងអ្ហ៎ស?

មីៈ ហ្នឹងហើយ! គាត់ថា អ្នករៀនហើយអន្តុយកៅអីរាប់ទៅវាភីងដូចដីរអីចឹង ។ បើបួសទៅបានអានិសង្ស ។ ចុះគាត់រៀនធម៌គាត់ទៅហ្នឹងទៅណា៎!

រ៉ាស៊ីៈ កាលគាត់ចូលបួសដំបូងហ្នឹងអាយុប្រហែលប៉ុន្មានទៅតាម៉ុកហ្នឹង?

មីៈ កាលបួសនេះខ្ញុំ...មិនទាន់២០ទេ...ខ្ញុំ១៩ ។ ហ្នឹងគាត់ប្រឡងហើយឲ្យបួសហ្នឹងណា៎ ។ បួសនេនហ្នឹងហើយបួសភិក្ខុហ្នឹង អាយុ៣០ណា៎បានសឹក ។

រ៉ាស៊ីៈ ពេលគាត់សឹកហ្នឹងបែកឬនៅ? នៅទេអ្ហី?

មីៈ នៅទេ ។ សឹកទៅមកការប្រពន្ធនៅភូមិប្រគាបនេះ ត្រូវជាជីដូនមួយគាត់ ។

កុសលៈ ប្រពន្ធគាត់ឈ្មោះអីកាលគាត់ការដំបូង?

មីៈ ប្រពន្ធ យាយខឹម ។

កុសលៈ ឈ្មោះ យាយខឹម ។ ស្អី ខឹម? កូនចៅអ្នកណាគេ?

មីៈ ជីដូនមួយគ្នាហ្នឹង

រ៉ាស៊ីៈ ជីដូនមួយគាត់ទៀត?

មី:	ខាងម្តាយណា៎! ម៉ែយាយ ខឹម ហ្នឹងបងយាយ សុច ។

រ៉ាស៊ី:	យាយខឹមហ្នឹងជីតាគាត់ឈ្មោះអីទៅ? ស្អី ខឹម?

មី:	ទេ...ដឹងតែឪពុក...មើលយាយ...ទូច...ហ្នឹងម្តាយណា៎ ហើយឪពុកដូចជាតាទឹងអីចេះឬអីទ្បី?
អញភ្លេចទៅណា៎ ។

កុសល:	យាយ ខឹម នៅស្រុកអីយាយ? ស្រុកនេះដែរអ្ហ៎ស?

មី:	នៅប្រគាប ខាងជើងវត្តនេះ ផ្ទះនៅខាងជើងត្រពាំងធំនេះ ។

រ៉ាស៊ី:	នៅក្នុងឃុំព្រាំងធំដែរចឹង?

មី:	ត្រពាំងធំ ប៉ុន្តែភូមិប្រគាប ឃុំត្រពាំងធំ ។

រ៉ាស៊ី:	ភូមិត្រគាតទេអ្ហ៎ស?

មី:	ប្រគាប!

រ៉ាស៊ី:	ប្រគាប?

មី:	អឺ! គាត់នៅភូមិប្រគាប

កុសល:	ពេលការហ្នឹងគាត់មានអាយុប៉ុន្មាន តាម៉ុក?

មី:	ការហ្នឹង?

កុសល:	បាទ!

មី:	ការហើយបានកូន២អត់ដែលនៅជាមួយប្រពន្ធហ្នឹងទៀត ។ បាត់រូបទៅ ។

កុសល:	ចឹងការហ្នឹងបានន័យថាគាត់សឹកសិន?

មី:	សឹកហើយមកការបងប្អូនហ្នឹងជីដូនមួយ ។

កល្យាណ:	សឹកភ្លាមការភ្លាមអ្ហីយាយ?

មី:	សឹកបានយូរដែរបានម៉ែឪគេ...

កុសល:	ចឹងប្រហែលអាយុ២៦?

រ៉ាស៊ី:	No! ថាសាមជាងហើយនៅបួស ។

មី:	ហ្នឹងហើយ ។ យី! បួសយូរណាស់ ។ បួសទាល់តែឆកក្បាលអស់ណា៎! ហើយបានសឹកមក
បងប្អូនហ្នឹងឲ្យការជីដូនមួយគ្នានេះ ។

កុសល:	ឆ្នាំណា? គាត់ការហ្នឹងឆ្នាំណា?

មី:	ដឹងឆ្នាំប៉ុន្មានទេវ៉ើយ

រ៉ាស៊ី:	ខ្ញុំហុកជាងទេ? កាលហ្នឹងក្នុងជំនាន់អីលោកយាយ? កាលគាត់ការហ្នឹងក្នុងជំនាន់ណា?
ជំនាន់លន់ណុលឬជំនាន់សីហនុ?

មី:	តាសីហនុ ។

រ៉ាស៊ី: ជំនាន់តាសីហនុអ្ហែស?

មី: អឺ!

រ៉ាស៊ី: អ៊ូ! ចឹងក្រោយ៧០ មុន៧០

រ៉ាស៊ី: ហុកជាង! ហុកជាង!

មី: កាល...កាលហ្នឹងសីហនុ...ព្រោះកាលដែលធ្វើនារីក្លាហានមានសង្គ្រាមហ្នឹងណា៎គាត់ការហើយ បាន កូន១ហើយ ហ្នឹងសីហនុហើយណា៎ ។

រ៉ាស៊ី: កូន១ហ្នឹងឈ្មោះអីគេទៅកូនហ្នឹង?

មី: ឈ្មោះអាខុម ។

រ៉ាស៊ី: កូនប្រុសអ្ហ៎ែស?

មី: កូនស្រី ។ អត់មានប្រុសទេ ស្រី ។

រ៉ាស៊ី: ស្រីទាំងពីរ?

មី: អាខុម អាហ៊ោ ។

រ៉ាស៊ី: ខុម ម៉ោ គោ?

មី: អាមួយអាហ៊ោ ។

រ៉ាស៊ី: ហ៊ោ?

មី: អឺ!

រ៉ាស៊ី: ប្រុសអ្ហ៎ែស?

មី: ស្រី ។

រ៉ាស៊ី: ស្រីទាំងពីរ?

មី: អត់មានកូនប្រុសទេ ។

រ៉ាស៊ី: អត់មានកូនប្រុសទេ? រួចចុះត្រកូល ដាក់ត្រកូលអីទៅ ខុម ហ្នឹង?

មី: អ៊ុង ដូចគ្នា ។

រ៉ាស៊ី: ចុះឥឡូវនៅរស់ឬស្លាប់ហើយ?

មី: ខុម ស្លាប់ហើយ នៅតែប្ដី តាមុត ។

រ៉ាស៊ី: ប្ដីឈ្មោះ មុត?

មី: មាស មុត ។

រ៉ាស៊ី: មាស មុត អ្ហ៎ែស?

មី: អឺ! តាមុតហ្នឹងដែលនៅផ្ទះនៅទួលគោកហ្នឹង ។

រ៉ាស៊ី: អ៊ូ! មាស មុត ហ្នឹងនៅទួលគោកហ្នឹងអ្ហែស?

មី:　　ផ្ទះគេនៅឯនោះ ប៉ុន្តែកាលដែលសារភាពហើយចូលមកគេធ្វើផ្ទះវីឡាមួយនៅទួលគោក ។

វ៉ាស៊ី:　　ហើយទៅម៉េចទៀតទៅលោកយាយ? កាលដែលគាត់ការហើយបានកូន២ហើយគាត់ទៅណាទៀតទៅ?

មី:　　គាត់បែកពីប្រពន្ធហ្នឹងទៅតស៊ូ ដល់កាលដែលរាជ្យឥស្សរៈហ្នឹងណា៎ បានគាត់ចូលមកជួបគេ គាត់យកប្រពន្ធហ្នឹងទៅនៅឯស្រុកលិចទៅ ។

វ៉ាស៊ី:　　អ្ហូ! គាត់ចូលទៅឥស្សរៈហើយបានមកយកប្រពន្ធទៅក្រោយ?

មី:　　អើ!

វ៉ាស៊ី:　　ស្រុកលិចហ្នឹងស្រុកអីគេស្រុកលិចហ្នឹង?

មី:　　ខេត្តកំពតនេះ ។

វ៉ាស៊ី:　　ខេត្តកំពតយើងនេះអ្ហី?

មី:　　នៅស្រែក្នុងនៅអីហ្នឹងណា៎! ហើយរហូតពីហ្នឹងទៅយកប្រពន្ធតាមរហូតទៅ ។

វ៉ាស៊ី:　　បានកូនប៉ុន្មានទៅពេលទៅពីរនាក់ប្តីប្រពន្ធហ្នឹង? បានកូនប៉ុន្មាន?

មី:　　កូនដូចជា...មើលវ៉ី...នៅឯនេះដែលបែកគ្នាដូចជា អាខុម អាហ៊ោ ហើយអាហេង អាគ្រូ

វ៉ាស៊ី:　　អាសេង អាគ្រូ?

មី:　　អាហេង

វ៉ាស៊ី:　　អាហេង?

មី:　　អើ! កូន៥នាក់ហើយហ្ន៎? មើល៍ មួយអាខុម ពីរអាហ៊ោ បីអាហេង បួនអាឆិច

វ៉ាស៊ី:　　ចុះម្នាក់ទៀត? កូនទី៥?

មី:　　ទេវ៉ី អញដូចជាភ្លេចទៅណា៎ កូនដូចតែប៉ុណ្ណឹងនាក់ទេ ។

វ៉ាស៊ី:　　តែបួនទេអ្ហេស? ដឹងគាត់ទៅជាមួយប្រពន្ធនិងកូន៤នាក់ទៅជាមួយ?

មី:　　ទៅជាមួយគ្នារហូតទាល់តែប្រពន្ធហ្នឹងទៅស្លាប់នៅថៃទៅ ។

វ៉ាស៊ី:　　ចឹង ហើយយាយម៉េចដឹង... ម៉េចក៏គាត់ចេញពីនេះទៅចឹង?

មី:　　ចុះបើអត់ចូលស្រុកផង គ្រាន់តែសឹកហើយមកការទៅគាត់បាត់ខ្លួនរហូតទៅ គាត់ទៅនៅតែក្នុងព្រៃ គាត់មិនមែនមកនៅរញ៉ិករញ៉ុកធ្វើស្រែធ្វើអីអត់ទេ គ្រាន់តែម៉ែឪហ្នឹង.. គាត់នៅវត្តមហាមន្ត្រី ម៉ែឪយកមកឲ្យការជីដូនមួយហ្នឹង ប្រពន្ធនៅធ្វើស្រែទៅ បានកូន១ហ្នឹង យូរៗគាត់មកចឹងទៅណា៎ បានកូន២ ហើយដល់ហើយទៅបានកាលដែលគាត់នៅតាកែវនេះ ហ្នឹងប៉ុលពតហើយណា៎ ហ្នឹងបានគាត់យកប្រពន្ធហ្នឹងទៅនៅជាមួយ ហើយដល់ហើយគាត់ យកទៅទុកនៅឯលាដឯអីនោះទៅណា៎ ។

វ៉ាស៊ី:　　ស្រុកលាដស្រុកអីនោះអ្ហេស? ស្រុកលាដខេត្តពោធិសាត់អីនោះអ្ហេស?

មី:	ហ្នឹងហើយ ។

រ៉ាស៊ី:	កាលហ្នឹងគាត់អាយុប៉ុន្មានហើយពេលដែលគាត់យកប្រពន្ធគាត់ទៅហ្នឹង?

មី:	ខ្ទង់សាមសិប ។

រ៉ាស៊ី:	អ្ហូ ខ្ទង់សាម... ខ្ទង់សាមលោកយាយថាទើបនឹងសឹកហ្នឹង? បើបានកូន៤ហើយ ខ្ទង់សែទេអ្ហី?

មី:	អើ ខ្ទង់ហ្នឹង ខ្ទង់ ៣៥ សាមអីហ្នឹង ។

រ៉ាស៊ី:	ហើយទៅម៉េចទៀតទៅ?

មី:	ដល់ហើយបែកគ្នាបាត់រហូតទៅ ទើបតែមរ្សិលមិញហ្នឹងឃើញមកទាំងអស់វិញ ។

រ៉ាស៊ី:	កាលពេលទៅលោកយាយថា មកប្រជុំនៅឯនេះជាមួយ...

មី:	អាហ្នឹងពេលបែក ។

រ៉ាស៊ី:	ពេលបែកឆ្នាំណា?

មី:	ឆ្នាំ៩៣ កាលបែកប៉ុន្មាន ៧៣ឬអីដែលបែកអាពត?

កល្យាណ:	បែកអាពតយាយអ្ហូស?

មី:	អើ!

រ៉ាស៊ី:	បែកអាពតនៅភ្នំពេញ៧៥ តែនៅឯនេះដឹងបែកមុនឬក៏បែកក្រោយ? ៧៣អ្ហូស?

កុសល:	តំបន់រំដោះហើយឯណឹងនោះ ។

មី:	រំដោះបែកដែលពួកភ្នំពេញចេញមកអស់ហើយណ៎ អាហ្នឹង៧៥អ្ហូស?

រ៉ាស៊ី:	បាទ ៧៥ ។ ពួកភ្នំពេញមកនេះ ។

មី:	អើ!

រ៉ាស៊ី:	ហើយចឹងគាត់មកឯនេះ?

មី:	គាត់មកប្រជុំប្រកាសហ្នឹង ។

រ៉ាស៊ី:	គាត់មកជិះអីមកកាលហ្នឹង?

មី:	ជិះឡានណ៎ ។

រ៉ាស៊ី:	ជិះឡានជាមួយនរណាខ្លះទៅ?

មី:	ចុះនរណាស្គាល់គេអស់ គេគ្រាន់តែថាអង្គការមកប្រជុំ ។

រ៉ាស៊ី:	អ៊ូ អង្គការមកប្រជុំអ្ហូស?

មី:	អើ! គ្រាន់តែប៉ុណ្ណឹង ហើយយើងអ្នកធ្វើប្រឡាយគេឲ្យធ្វើទៅ អ្នកដែល...

រ៉ាស៊ី:	មាននរណាខ្លះអង្គការហ្នឹងលោកយាយ? មានពុសូរអ្នកជិតខាងគេនិយាយប្រាប់អីទេ?

មី: វាអត់ស្គាល់ទេ ព្រោះយើងបងប្អូនចេញពីភ្នំពេញមកគេឲ្យទៅនៅអាពួកត្រៀមទៅណា៎ ហើយអាពួកពេញសិទ្ធិទទួលភ្ញៀវទៅណា៎ ។

រ៉ាស៊ី: ចុះយាយកាលហ្នឹងជាប្រជាជនពេញសិទ្ធិឬក៏ប្រជាជនត្រៀម?

មី: ត្រៀម ។

រ៉ាស៊ី: ត្រៀមដែរ?

មី: ចុះមាននរណានៅ?

កល្យាណៈ ក្រែងយាយនៅឯនេះអ្ហស?

មី: នៅឯនេះប៉ុន្តែបងប្អូនភ្នំពេញទាំងអស់ ហើយប្ដីយាយសក្ដិ១ប៉ូលិសទៀត (លោកយាយសើចកក្អឹក) ។

រ៉ាស៊ី: អូ៎! ចឹងត្រៀមត្រូវហើយចឹង

មី: ត្រៀមហើយ! ប្ដីក៏ទាហាន អូនៃ...ប៉ូលិស ទាហាន២០ឆ្នាំធ្វើប៉ូលិស ហើយបងសុទ្ធតែស្រុកបារាំង ហើយអាប្អូននោះស្រុកបារាំងដែរ ។ ហើយមានអ្នកណាគេទៅឲ្យចូលវង់អីសុទ្ធតែពួកចឹង ។

រ៉ាស៊ី: ហ្នឹងហើយ គេឲ្យនៅក្រៅ ។

មី: ហើយដល់បែកភ្នំពេញស្លាប់អស់ នៅ១នៅ២រើមរវាមមកគេឲ្យទៅនៅ...ប្រជុំគេឲ្យប្រជុំដោយខ្លួនទេណា៎ ត្រពាំងត្នោតឯណោះ ពួកពេញសិទ្ធិគេប្រគាបនេះ ។

រ៉ាស៊ី: អូ៎ ចឹងប្រជុំនៅឯនេះដោយមានចូលរួមអី...គេថាប៉ុលពតជងអ្វីមែនទេ?

មី: មានតែប្រធានភូមិហ្នឹង

រ៉ាស៊ី: តែប្រធានភូមិទេចូលរួមហ្នឹង?

មី: ប្រជាជនគេប្រជុំឯប្រគាបនេះ ហើយពួកមកពីភ្នំពេញពួកត្រៀមអីគេឲ្យប្រជុំនៅត្រពាំងត្នោតឯណោះ ។ គេមិនមែនឲ្យចូលជាមួយគ្នាទេណា៎ ។

រ៉ាស៊ី: ហើយម៉ោប្រជុំហ្នឹង លោកយាយមានឮសួរគេថាមានអី...ដូចថាទាហានម៉ោ ទាហានអីមានពួកចិនពួកអីជងអ្វីកាលហ្នឹង?

មី: ពេលដែលប្រជុំគេហៅយើងធ្វើអីចេះ អ្នកដែលពាក់ព័ន្ធមានបងប្អូននៅភ្នំពេញ ឥឡូវបើសិនណាជាគេហៅបានមកតើហ៊ានសម្លាប់ចោលទេ ។

រ៉ាស៊ី: អ្នកណាគេនិយាយចឹង?

មី: ពួកប្រជុំហ្នឹង ពួកឃុំពួកអីគេហ្នឹង ។

រ៉ាស៊ី: ពួកឃុំគេនិយាយទេអ្ហស?

មី: អើ! គេសួរចិត្តយើងមើលស្មោះជាមួយគេដែរឬអត់ណា៎ ហើយគេកាត់ទោសសីហនុ គេឲ្យយើង ប្ដេជ្ញាលើកដៃថាដេរចឹងទៅណា គេឲ្យដេរហើយគេដុតរូបសីហនុហ្នឹងទៀត ។ គេធ្វើរូបសីហនុហ្នឹង រុំចំបើងហើយគេធ្វើពាក់ប៉េរ៉ែដូចសីហនុចឹងទៅ ហើយគេឲ្យប្ដេជ្ញាហើយ គេដុតរំលាយចោលអាសីហនុ ចឹងទៅណា៎ ។ ហើយអញម៉េចនឹងហ៊ានថា អញចេះតែខ្លាច ។

រ៉ាស៊ី: ហ្នឹងប្រហែលថ្ងៃណា? ខែណា?

មី: ហ្នឹងដែលមុនបែកភ្នំពេញហ្នឹង គេរៀបចំចឹងគេរ៉ៃភ្នំពេញណា ។

រ៉ាស៊ី: មុនបែកភ្នំពេញបន្តិចបន្តួចហ្នឹងអ្ហេស?

មី: ហ្នឹងហើយ ។ ដូចថាគេចូលព័ទ្ធភ្នំពេញហើយគេថាកម្ទេចហើយហ្នឹងណា អាហ្នឹងគេមកប្រជុំ ប្រជាជនគេធ្វើអីចឹង ហើយយើងគេមិនមែនឲ្យមកមើលទេ មានតែពួកពេញសិទ្ធិទេណា៎ យើងគេឲ្យធ្វើប្រឡាយ ធ្វើអីឯណោះ ។

រ៉ាស៊ី: ហើយគេអ្នកដឹកនាំមកប្រជុំនៅឯហ្នឹងដែលថាមកដុតទីងមោងធ្វើជារូបសីហនុហ្នឹងច្រើនតែ ពួកណា ពួកដឹកនាំមកហ្នឹង?

មី: ខ្លះគេថាអាពួកចៅហ្វាយស្រុកចៅហ្វាយខេត្តខាងគេហ្នឹងណា៎ ។

កុសលៈ ហើយតាម៉ុកនៅហ្នឹងទេពេលហ្នឹង?

មី: តាម៉ុកអត់ទេ មានតែអ្នកធ្វើការ តាម៉ុកមិនដែលចូលទេ ទាល់តែថ្ងៃបែកភ្នំពេញបាន មកប្រជុំ ។

រ៉ាស៊ី: ថ្ងៃបែកភ្នំពេញមកប្រជុំ ចុះឥឡូវថ្ងៃបែកភ្នំពេញមកប្រជុំហ្នឹងតើគាត់មកជាមួយអ្នកណា គេខ្លះ?

មី: មកគ្នាគាត់ហ្នឹងអត់អ្នកណាស្គាល់ផង

រ៉ាស៊ី: សុទ្ធតែពួកធំៗហ្នឹងអ្ហ?

មី: អើ!

កុសលៈ អឺបានស្ដាប់ទេ?

មី: អត់ទេ!

កុសលៈ អត់បានស្ដាប់ទេ?

មី: អើ! យើងពួកត្រៀមគេឲ្យទៅធ្វើប្រឡាយ អាពួកពេញសិទ្ធិគេនៅស្ដាប់ណា៎

រ៉ាស៊ី: ហើយចុះមានដែលឮសួរពួកពេញសិទ្ធិគេនិយាយថាមាន ប៉ុល ពត អីមកចូលរួមទេ?

មី: ថ្ងៃហ្នឹងគេគ្រាន់តែអឺចេះណា៎ អាពួក១៧ហ្នឹងវែកដីទៅរ៉ាស្គមៗ កំណត់បាយរបបបន្តិចៗ ណា៎ តែស្គមហើយរយ៉េវយ៉ៃអីគេឲ្យថយ ហើយដល់ខោអាវស្អាតៗដូចប្រធានភូមិប្រធាន អីហ្នឹងគេនៅអមដួវចំអីចឹងទៅណា៎ ។

រ៉ាស៊ី: ចាំទទួលហ្នឹងអ្ហេស?

មី: ហើយឥឡូវបើឲ្យអ្នកធំៗឃើញវាដូចខូចនយោបាយគេណា៎ គេឲ្យចេញទៅវាលទៅអត់ឲ្យចូលទេ គេហៅតែអ្នកដែលគេបាយទឹកពេញបរិបូណ៌ហ្នឹងគេហៅចូលទៅទទួលទៅណា៎ ហើយប្រធានភូមិគេអត់ចេះអក្សរទេ ដែលដូចអាម៉េចអ្នកភ្នំពេញគេនិយាយថា សូមគោរពនែ៎ៗៗ គេធ្វើគ្រាប់ពួកហ្នឹងណា៎ ដូចអីចឹង ហើយគេមិនមែនឲ្យយើងចូលទេណា៎ បើថាមកពួកយើងមានប្រធានកងគេហៅចេញទៅធ្វើការហើយណា៎ ហើយពួកពេញសិទ្ធិគេហៅចូលមកទទួលហើយ ។

រ៉ាស៊ី: កាលហ្នឹងមានតាម៉ុកចូលរួមទេ?

មី: តាម៉ុកមកមួយភ្លែតហ្នឹង មកប្រហែលមិនដល់មួយម៉ោងផង ម៉្លោះហើយមិនបាន...

រ៉ាស៊ី: មកជាមួយអ្នកណាខ្លះទៅ?

មី: ចុះដឹងអីបើ...

រ៉ាស៊ី: មានពុស្សូរគេនិយាយទេ?

មី: មាន គេថា ប៉ុល ពត អី

រ៉ាស៊ី: ស្អីទៀត?

មី: ដឹងស្អីរ៉ុ! អ្នកណាគេទៅប្រាប់យើង? គ្រាន់តែថាថ្នាក់លើមក អង្គការថ្នាក់លើមក យើងកុំចង់ដឹង គេឲ្យធ្វើអីធ្វើហ្នឹងទៅ គេនិយាយអីចឹងហើយយើងទៅហ៊ានសួរគេម៉េចបាន ។

រ៉ាស៊ី: ហើយចុះក្រោយមកទៀតពេលដែលចេញទៅហ្នឹងណា៎ ពេលដែលគាត់ចេញពីប្រជុំហ្នឹងទៅវិញទៅ លោកយាយមានដែលឃើញគាត់ទៀតទេ?

មី: អត់

រ៉ាស៊ី: ទាល់តែឆ្នាំណាបានឃើញ?

មី: ទាល់តែរត់

រ៉ាស៊ី: ទាល់តែរត់ រត់ឆ្នាំណារត់ហ្នឹង?

មី: ចុះយើងកាលដែលវៀតណាមឡើងឆ្នាំណា? បែកភ្នំពេញហើយណា៎ ៧៩អ្ហេស?

រ៉ាស៊ី: បែកភ្នំពេញ៧៩ដដែលហ្នឹង

មី: អឺ!

កល្យាណៈ ៧៩ហើយ គាត់ថាវៀតណាមឡើង បែកភ្នំពេញវៀតណាមឡើងអ្វីយាយ?

មី: ហ្នឹងហើយ វៀតណាមដេញឡើងតាម...

កុសលៈ កាលដែលទៅពោធិសាត់ហ្នឹងអ្វី?

មី: ហ្នឹងហើយ

កល្យាណៈ ចឹងជួបគាត់ពេលហ្នឹងម្តងទៀត?

មី: ទៅដល់ហ្នឹងបានឃើញណា៎ ដល់ពោធិសាត់ណា៎

រ៉ាស៊ី: លោកយាយរត់ពីនេះទៅដែរអ្ហស?

មី: រត់ រត់ហ្នឹងមិនមែនតិចទេណា៎ ប្រជាជនហ្នឹងឲ្យណែនទៅ រាប់លានណា៎ គ្រាន់តែគេកត់គេថា ៧លាន អញថាផាប់ហើយ ទៅទាំងម៉ែ ទាំងកូន ទាំងឪ ចេះតែដើរ យប់ឯណាដេកនឹងដី ចឹងទៅណា៎ ហើយដល់វៀតណាមទាន់អាដូវឡើងទៅអណ្តូងហួសអន្លង់វែង មិនមែនអន្លង់វែងនេះទេណា៎ អន្លង់វែងពោធិសាត់ហ្នឹងណា៎ ។

រ៉ាស៊ី: អន្លង់វែងពោធិសាត់នេះ មិនមែនអន្លង់វែងសៀមរាបទេអ្ហស?

មី: អើ! ចម្ការក្រូចគេឯនេះណា៎ បានវៀតណាមទៅទាន់ឡាន៤-៥ ហើយវាសួរថា ថាធ្វើឌីៗ ឲ្យនៅស្រុកឯណាឲ្យមកហ្នឹងវិញ ។

រ៉ាស៊ី: អូ៎! វៀតណាមថាអីចឹងអ្ហស?

មី: អឺ! ថាស្រុកនៅឯណាទៅឯហ្នឹងវិញ ហើយដល់ហើយទៅបានបត់ក្បាលមកវិញមក ។

រ៉ាស៊ី: មិនមែនតាម៉ុកដេញទេអ្ហស?

មី: ទេ! វៀតណាមតាមកៀរមកវិញណា៎

រ៉ាស៊ី: ចុះយាយនិយាយមិញថាតាម៉ុកដេញឲ្យមកវិញ ថា...

មី: តាម៉ុកគាត់ដេញហើយ ប៉ុន្តែយើងទៅនៅដល់ហ្នឹងហើយគាត់ថាមកធ្វើអី យើងប្រជាជនអាហ្នឹងដែលគាត់ជួបមួយភ្លែតណា៎ ប្រជាជនទំរត់ធ្វើអី អាណាគេវៃប្រជាជន ទៅផ្ទះទៅសម្បែងវិញទៅ ហើយយើងនៅស្មៀម គ្រាន់តែតាម៉ុកទៅផុតអារថក្រោះចូលគ្រឹបសុទ្ធតែវៀតណាម ហើយវៀតណាមបានដេញថាឲ្យត្រឡប់ក្រោយវិញ ត្រឡប់ក្រោយវិញ វៀតណាមមានគុណដែរកុំថាគ្នា ដឹកពួកដែលប្រពន្ធពួកអីដែលនៅភ្នំពេញ ពួកទូតណា៎ យកទៅទម្លាក់ជ្រោះ វៀតណាមដឹកបង្ហោងទៅប៉ុន្មានឡានទៅទម្លាក់ឲ្យវារឡើងទេតើ វារឡើង ហើយគ្រាន់តែថាកុំភ្លេចគុណគេអី គេជួយរំដោះយើងណា៎ ។

រ៉ាស៊ី: ហើយតាម៉ុកមានបងប្អូនប៉ុន្មាននាក់យាយ?

មី: បងប្អូនគាត់៥ឬ៦មិញហ្នឹង?

រ៉ាស៊ី: ដឹងប៉ុន្មានដែរ ខ្ញុំភ្លេចបាត់ហើយមិញ ។

កល្យាណៈ ៦ ស្រី៣អ្ហីយាយ? ស្រី៣ ប្រុស៤អ្ហស?

មី: អូ៎! ស្រី៤វិញ ។

កល្យាណៈ ស្រី៤អ្ហស?

មី: អឺ! កាពូនហើយដែល...ហ្នឹងកូន..តាម៉ុកហើយបងចុក បងចុកហើយកាពូននេះ កាពូនហើយ បងចំ បងចំហើយមីគួប ហ្នឹងកូនស្រីណា៎ គួបហ្នឹងហើយបានមីគឿន គឿនហើយមីគេន ស្រី៤ ប្រុស៣ ។

វ៉ាស៊ី: ហើយចុះពួកម៉ាកគាត់ជិតស្និទ្ធនោះឈ្មោះអីយាយ?

មី: តាម៉ុក?

វ៉ាស៊ី: បាទ!

មី: អាណាដឹង?

វ៉ាស៊ី: ចុះថាទៅអីណាវៀតណាមអីណានោះ?

មី: ពួកម៉ាកដែលគាត់មកហ្នឹងមានតែពួក ញៀម ស៊ិន ពួកដែលមកហាត់ វៀតណាមហ្នឹងណា៎ មកដាក់នៅព្រៃលិចហ្នឹង សុទ្ធតែវៀតណាម ញៀម ស៊ិន ហ្នឹង និងលោកយិនលោកអីហ្នឹង គេនៅ...

វ៉ាស៊ី: មុនបែកភ្នំពេញអ្ហេស?

មី: មុន តាំងពីឥស្សរៈមកនោះ

កុសល: ចឹងតាម៉ុកជិតស្និទ្ធនឹងវៀតណាមណាស់ចឹង?

មី: យី! នៅតែជាមួយពួកវៀតណាមទេតើ

វ៉ាស៊ី: គាត់ចេះវៀតណាមទេ?

កុសល: រឺលតែម្តង?

មី: រឺលហ្នឹង

វ៉ាស៊ី: ចេះរឺលតែម្តង?

មី: ហើយបើមិនចេះម៉េចនឹងដើរជាមួយគ្នាបាន?

វ៉ាស៊ី: អូ៎! ចឹងអ្ហេស?

កល្យាណ: យាយធ្លាប់ឮគាត់និយាយវៀតណាមដែរ?

មី: បើបានជួបបានឮ ប៉ុន្តែគាត់ដែលនៅឯនេះដែលវៀតណាមវាមកហ្នឹងវាហាត់ណា៎ ហើយ គាត់នៅឈរមើលហាត់ជាមួយគ្នាហ្នឹង គាត់និយាយគ្នា

កុសល: ហាត់អីគេ? ហាត់ទ័ពអ្ហេស?

មី: វៀតណាមដែលមកហ្នឹងខ្ទង់៣០០វៀតណាម មិនមែនតិចទេ ពួកញៀមស៊ិន ពួកអីហ្នឹងណា៎

កុសល: ហាត់យុទ្ធសាស្ត្រទ័ពហ្នឹងអ្ហេស?

មី: ហ្នឹងហើយ វាមកនៅហ្នឹង ហើយតាម៉ុកហ្នឹងគាត់ដើរ គេថាឥស្សរៈកាលដំបូងហ្នឹងចេញ មកណា៎ គាត់សឹកពីបួសគាត់ចូលហាណូយណា៎ ហើយដល់ហើយបានមកជាមួយវៀតណាម

ហ្នឹងគាត់ចេញធ្វើឥស្សរៈក្នុងព្រៃណា៎ ហើយសួរមើល គាត់ថាលោក យិន ញ៉ែម ស៊ិន ហ្នឹងសុទ្ធតែដៃគូគាត់ទេតើ ដែលមកជំរុំបូង ចូលមក...

កុសលៈ ញ៉ែម ស៊ិន ដូចស្តាប់ទៅដូចជាកម្ពុជាក្រោមអ្ហេស?

មីៈ ដឹងអាម៉េចបើនិយាយខ្មែរមិនច្បាស់ផង

វ៉ាស៊ីៈ សង្ស័យខ្មែរកម្ពុជាក្រោមហើយតាមមើល

កល្យាណៈ គាត់ទៅឥស្សរៈឆ្នាំណាយាយ?

មីៈ ហឺ...ឆ្នាំណា ឥស្សរៈហ្នឹងតាំងពីយាយមិនទាន់ការម៉េះនោះ

វ៉ាស៊ីៈ លោកយាយប្អូនតាម៉ុកទេចឹងអ្ហេស?

មីៈ ប្អូន

វ៉ាស៊ីៈ ប្អូនគាត់ប៉ុន្មានឆ្នាំយាយ?

មីៈ តាម៉ុកខាល ជោះ រោង ម្សាញ់ មមី ប្អូន៦ឆ្នាំ

កុសលៈ ចាំច្បាស់ហើយអ្ហេសលោកយាយថាតាម៉ុកកើតឆ្នាំខាល? ខែអីខែបារាំង? ថ្ងៃអីចាំទេ?

មីៈ អាល័យតែដឹងខែ? ដឹងតែឆ្នាំខាល ។

វ៉ាស៊ីៈ ខាល ខែខ្មែរខែអី?

កល្យាណៈ ចឹងគាត់ចិតជាងហើយអ្ហីយាយ? ខាលចិតប៉ុន្មានហើយ?

មីៈ ៧៨

វ៉ាស៊ីៈ ចឹងលោកយាយហុកជាងហើយ ៦៨ហើយអ្ហេស?

មីៈ យាយចិតជាងហើយហ្នឹង ចិតគត់ហើយហ្នឹង

វ៉ាស៊ីៈ ចិតគត់ហើយរាប់ឆ្នាំខ្មែរហ្នឹង?

មីៈ យាយមិនសូវ...ទាល់តែគេដែលស្រករគាត់ហ្នឹងបានដឹងប្រវត្តិពីតូចមក យាយប្អូនហ្នឹង...

វ៉ាស៊ីៈ ចុះលោកយាយមានដឹងចំណង់ចំណូលចិត្តគាត់ពីក្មេងចូលចិត្តធ្វើអីដែរ?

មីៈ ចុះបើអត់ដែលបាននៅឃើញគ្នាផងហ្នឹង គ្រាន់តែដឹងថាភូមិគាត់នៅប្រគាបនេះ ហើយដឹងថាគាត់នៅនឹងឪពុកបួសឯនោះណា៎ ហើយមិនមែនជិតដល់បានដើរលេងដើរសើចនឹងគ្នាអត់ទេ គ្រាន់តែនៅជិតគ្នា ភូមិជិតគ្នាណា៎ ។

កល្យាណៈ អ៊ូ! ភូមិគាត់ពីក្មេងគាត់នៅខាងប្រគាបអ្ហីយាយ?

មីៈ ប្រគាប

កុសលៈ ឪពុកគាត់ខ្មែរសុទ្ធអ្ហេស?

មីៈ ខ្មែរ

កុសលៈ ខ្មែរសុទ្ធឬក៏ខ្មែរកាត់អី?

មី:	ខ្មែរសុទ្ធ

កុសល:	សុទ្ធតែម្ដង ម្ដាយសុទ្ធដែរ?

មី:	ម្ដាយក៏ខ្មែរ បងប្អូនភូមិប្រកាបនេះសុទ្ធតែបងប្អូនគាត់ អត់ចេះទៅមានអីចេះអី បើគាត់បួសរៀន ឪពុកហ្នឹងបួសហើយរៀនធម៌ បង្រៀនលោក អាចារ្យបង្រៀនលោកណា៎ សត្វគេសម្លាប់នឹងផ្ទះអត់ហូបទេ ហូបបាយតែជាមួយចេកជាមួយស្ករឪពុកនោះ ហើយគាត់នៅតែក្នុងវត្តធ្វើសីលភាវនាតែនឹងវត្តហ្នឹង ។

កុសល:	ហើយដល់កូនទៅជាទាហានទៅវិញ ចូលចិត្តខាងប្រយុទ្ធចឹងទៅ?

មី:	ចុះបើគាត់កូន ម៉េចនឹងដូចឪណ៎ស

កុសល:	តែចង់ថាគាត់ជាអ្នកបួសណា៎លោកយាយ

មី:	បួសហ្នឹងអត់ឲ្យកូនធ្វើអីចឹងណា៎ គាត់ឲ្យបួសណា៎ ដល់ហើយគាត់សឹកទៅគាត់អត់ហ៊ានចូល ឪពុកមិនឲ្យសឹកគាត់ចូលទៅនោះទៅណា៎ ទៅទាហានវៀតណាមទៅណា៎ ហើយដល់អត់ត្រូវគ្នាទេ ។

វ៉ាស៊ី:	ឪពុកនិងកូនហ្នឹងអត់ត្រូវគ្នាទេ?

មី:	អត់ទេ គាត់ថាអាពាល

វ៉ាស៊ី:	ឪពុកហៅតាម៉ុកហ្នឹងអាពាល?

មី:	អឺ! កូនហ្នឹងពាល អត់ស្ដាប់បញ្ញាឪពុក

កុសល:	ដោយសារតាម៉ុកទៅវៀតណាមហ្នឹងអ្ហេស?

មី:	ហ្នឹងហើយ

កុសល:	ឪពុកហ្នឹងហៅថាអាពាល?

មី:	គាត់ថាចឹង គាត់ថាឪពុកឲ្យបួសទៅសឹក លោកថាត្រង់គាត់ទៅធ្វើអីចឹង គាត់ថាគាត់... ចុះគាត់ទេសនា គាត់បួសណា៎ គាត់ថាកុំឲ្យស៊ីសង កុំឲ្យលើសខុះ កុំឲ្យ... គាត់ទេសន៍គាត់ណែនាំអីចឹងណា៎ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ គាត់មិនមែន...ហើយបើថាមាន់ធ្វើហើយអត់ហូបទេ ជ្រូកហ្នឹងបើគេធ្វើហើយពុសំឡេងអត់ហូបទេ ដល់កូនហ្នឹងវាមានហ៊ានមកជិតឪពុកបើឪពុកធ្វើអាចារ្យ ។

កល្យាណ:	រួចបងប្អូនគាត់ហ្នឹងទៅខាងឥស្សរៈតែម្នាក់គាត់ទេអ្ហេសយាយ?

មី:	តាម៉ុក?

កល្យាណ:	ចា៎!

មី:	ទៅទាំងអស់ ងាប់អស់រលីងហើយហ្នឹង

កល្យាណ:	ទៅទាំងអស់?

មី:	អឺ! ប្អូនប្រុសគាត់ស្លាប់អស់ហើយ

វ៉ាស៊ី:	នៅសល់តែតាម៉ុកមួយទេអ្ហែស?

មី:	នៅតែតាម៉ុកទេ

កល្យាណៈ	ប្អូនៗប្រុសគាត់ហ្នឹងទៅជាមួយគាត់ចឹងដែរ?

មី:	ខ្លះគណៈឃុំ ខ្លះមេទ័ព ប៉ុន្តែស្លាប់អស់ហើយហ្នឹង បងចុកហ្នឹងក៏ស្លាប់ បងចំក៏ស្លាប់ បងប្អូន ៣នាក់ហ្នឹង

វ៉ាស៊ី:	តាចុកហ្នឹងកាលជំនាន់ហ្នឹងតួនាទីគាត់អីគេ?

មី:	ធ្វើចៅហ្វាយស្រុកនៅព្រៃល្វាឯណោះ ហ្នឹងតាចុកហ្នឹង ប៉ុន្តែគេហៅតាចុង

កល្យាណៈ	ព្រៃអីយាយ? ចៅហ្វាយស្រុកនៅឯណាយាយ?

មី:	ព្រៃល្វាហើយ

កល្យាណៈ	ព្រៃល្វាអ្ហែស?

មី:	អឺ! ហ្នឹងប៉ុន្តែគេដាក់អីចុងទេ កាលហ្នឹងគេមិនហៅចុកដូចនៅនេះទេ

វ៉ាស៊ី:	អីចុង! ចុះតាចំនោះ?

មី:	ចំគណៈឃុំពកត្របែកនេះ

វ៉ាស៊ី:	អ្ហូ! គណៈឃុំ?

មី:	ហ្នឹងហើយ

វ៉ាស៊ី:	ឃុំវែកអ្ហែស?

មី:	ពកត្របែក

វ៉ាស៊ី:	ពកត្របែក? ក្នុងស្រុកយើងនេះដែរអ្ហែស?

មី:	ហ្នឹងហើយ ហើយដល់រត់ទៅស្លាប់បាត់អស់ទៅណា៎ ហើយតា និត ប្តីយាយពូនហ្នឹង ចៅហ្វាយស្រុកនៅនរាយណ៍ ចុងឃុំ...តានីនេះ

វ៉ាស៊ី:	តានីទូកមាសយើងកំពតនេះហ្នឹងអ្ហែស?

មី:	ហ្នឹងហើយ ហើយស្លាប់បាត់ដែរ ស្លាប់អស់ហើយ

វ៉ាស៊ី:	ស្លាប់ហ្នឹងស្លាប់ដោយសារជំងឺឬក៏ស្លាប់ដោយសារយ៉ាងម៉េច?

មី:	ស្លាប់...ដឹងម៉េចបើរត់ទៅវាបាត់ទៅ ដល់ជួបជុំគ្នាសួររកអាខ្លះស្លាប់ភ្នំកំចាយ អាខ្លះស្លាប់អី កាលរត់វៀតណាមហ្នឹងវារត់ទៅដាច់បាយដាច់ទឹកទៅវាស្លាប់ទៅណា៎ ហើយអ្នកមកគេថាស្លាប់ឯនេះ ស្លាប់ភ្នំកំចាយ ស្លាប់ភ្នំអី ហ្នឹងដល់យើងវាបានសុខចឹងទៅណា៎ ប៉ុន្តែយាយពូនហ្នឹង គាត់អត់ដែលទៅណាទេ ភ្ជួរខ្លួនឯង រាស់ខ្លួនឯង ស្ទូងខ្លួនឯងៗ

វ៉ាស៊ី:	អ្ហូ! ភ្ជួរទៀត?

មី:	ភ្លូរ ឥឡូវក៏នៅតែភ្លូរដែរ មើលដៃគាត់អត់មានក្រចកទេ រិចអស់ហើយ

កុសល:	មាំណាស់ហ្ន៎

មី:	ភ្លូរ រាស់ បោកស្រូវ

កល្យាណ:	គាត់ចំណាស់លោកយាយទេ?

មី:	ចំណាស់ហើយ បួន២ឆ្នាំ ប៉ុន្តែចាស់ដូចតែគ្នាចឹង

រ៉ាស៊ី:	នៅភ្លូរបានទៀត

មី:	ភ្លូរ ហើយរកស៊ីបោកស្រូវយប់បើដឹក២រទេះមកបោកទាល់តែហើយទៅ ចុះបើអត់មាននរណា បើមានអាម៉ុលមួយទៅនៅឯនោះហើយ ។

រ៉ាស៊ី:	ប្តីគាត់ស្លាប់យូរហើយចឹង?

មី:	ស្លាប់កាលរត់ហ្នឹង ហើយផ្ទះហ្នឹងនៅតែម្នាក់ឯងទេ

កល្យាណ:	ចុះកាលតាម៉ុកមកប្រជុំឯនេះ ប្រជុំហើយអត់មានមកលេងអ្នកភូមិសាច់ញាតិអីអត់ទេ?

មី:	អត់ទេ

កល្យាណ:	អត់សោះតែម្តង?

មី:	អត់មានមកទាក់ទងញាតិសន្តានអីទេ ជួបហ្នឹងមិនទាំងងាកមើលផង ចិត្តដាច់ណាស់ណា៎

រ៉ាស៊ី:	គាត់យល់ថាម៉េចបានជាគាត់មិនមករវីរវល់បងប្អូនសោះអីចឹង?

មី:	គាត់ថាគាត់បានជាអីចឹងហើយកុំឲ្យប៉ះពាល់ញាតិមិត្តក្នុងស្រុកបងប្អូនអី ងាប់ៗតែគាត់ រស់ៗតែគាត់ គាត់និយាយចឹងតែម្តង បើឃើញហៅទៅ ស្គាល់ហ្នឹងហៅគ្រាន់តែហើយ នាំគ្នារត់មកធ្វើអី ផ្ទះក៏មិននៅ យើងហ្នឹងអ្នកសង្គ្រាមអីដែរ គាត់និយាយតែប៉ុណ្ណឹងទេ នៅផ្ទះនៅស្រុកទៅមិននៅ អាណាគេទៅវៃប្រជាជន ក្រែងគេវៃយកប្រជាជនអ្ហស នាំគ្នាមកធ្វើអី ។

កុសល:	ចឹងគាត់តាំងចិត្តថាគាត់ជាអ្នកសង្គ្រាម ហើយយើងមិនមែនអ្នកសង្គ្រាមកុំតាមគាត់? គាត់ស្លាប់រស់តែគាត់?

មី:	អឺ! តាមធ្វើអី គាត់ថាឯងហ្នឹងអ្នកវៃអ្នកកាប់អី ក្រែងយើងហ្នឹងអ្នកស្ងួងអ្នកដកអ្ហី ប្រជាជនគេវៃ គេវៃយកប្រជាជនណា៎ ហើយរត់ចោលស្រុកចោលទេសមកធ្វើអី នាំគ្នាទៅផ្ទះទៅសម្បែងវិញ ។

កុសល:	តាមការដែលលោកយាយជួបចុងក្រោយហ្នឹងតើគាត់ជាមនុស្សអឺ...លោកយាយអាចប្រាប់ថាគាត់ជាមនុស្សម៉ឺងម៉ាត់ ឬក៏ជាមនុស្សរបៀបទាហាន ឬក៏គាត់មានលក្ខណៈដូចជាអាចារ្យ?

មី:	តាម៉ុកដែលដើរហ្នឹងអត់ដែលកាន់កាំភ្លើងកាន់អីទេណា៎

កុសល:	អត់ដែលកាន់កាំភ្លើងទេ?

មី:    អត់ទេ ជួបហ្នឹងដែនទេទេណា៎ គាត់គ្រាន់តែចាត់...ទេបើនេះវារបៀបគាត់អ្នករៀបចំចាត់ឲ្យគេធ្វើទៅណា៎ គេហៅតា១៥ទេតើ ។

វ៉ាស៊ី:    អ៊ូ! តា១៥អ្ហូស? គេហៅតា១៥អ្ហូស?

មី:    អឺ! ទៅកាលហ្នឹងគេហៅតែតា១៥ទេ

វ៉ាស៊ី:    កាលជំនាន់ប៉ុលពតហ្នឹងអ្ហូស?

មី:    គាត់ធ្វើហ្នឹងមិនមែនបាញ់មិនមែនអីអត់ទេ គ្រាន់តែបញ្ជាអ្នកនេះធ្វើនេះ អ្នកនេះធ្វើនេះ មុខសញ្ញាអីចេះៗៗជាមួយ ខៀវ សំផន ហ្នឹងណា៎

វ៉ាស៊ី:    ជាមួយ ខៀវ សំផន អ្ហូស?

មី:    អឺ! ធ្វើហ្នឹងធ្វើដើរតែជាមួយគ្នាហ្នឹងណា៎ ។

វ៉ាស៊ី:    អ្នកណាគេអ្នកហៅគាត់ថាតា១៥?

មី:    គេដាក់ផ្សារចឹង គាត់នៅស្រុកខេត្តតាកែវយើងគេមិនហៅស្រុក១០៥ ហើយគេហៅតា១៥ ស្រុកកំណើតនៅតាកែវណា៎ ហើយគាត់ដាក់ផ្សារ១៥ចឹងទៅណា៎ ។

កុសល:    ដោយសារតែស្រុកនៅហ្នឹងឈ្មោះ១០៥?

មី:    អឺ! ខេត្តតាកែវគេហៅស្រុក១០៥ ។

កល្យាណ:    រួចចុះគាត់ដូរឈ្មោះមកដាក់ឈ្មោះតាម៉ុកហ្នឹងតាំងពីឆ្នាំណាយាយ?

មី:    ទាល់តែរត់ទៅហើយហ្នឹងបានពុគេហៅតាម៉ុកៗ ពីតូចគេហៅតែតាជឿនហ្នឹង

កុសល:    ឈ្មោះបងប្អូនគ្នាទៀតណា៎ ជឿន ចុក ចំ ខ្មែរសុទ្ធតែម្តងឈ្មោះណា៎

មី:    អ៊ុង ជឿន អ៊ុង ចុក អ៊ុង ចំ

កុសល:    ឈ្មោះហ្នឹងខ្មែរសុទ្ធតែម្តង ពីរម៉ាត់

មី:    ហើយដល់កូនស្រី មីកាពូន មីគួប មីគេន មីគឿន អត់ដឹងអីទេ ខ្មែរស្មោះតែម្តង ឪពុកក៏ខ្មែរ យាយក៏ខ្មែរ

កុសល:    បើតាមអីធ្លាប់ពុ បើតាមអីជួបចុងក្រោយ តើគាត់កាចឬក៏ស្លូត?

មី:    ស្លូតទេណា៎

កុសល:    និយាយទន់ភ្លន់ឬក៏យ៉ាងម៉េច?

មី:    ផ្អែម ប៉ុន្តែបើជួបមិនគ្រាន់តែប៉ុណ្ណេះទេ បើជួបប្រជាជនមានអីឲ្យគេអស់រលីង

កុសល:    ប្រជាជនអត់ខ្លាចទេ?

មី:    អត់ទេ បើខោអាវស្បៀកគេថាសុំឲ្យអស់រលីង ហើយថាធ្វើហ្នឹងក្លួយឯងថាមានអីនឹងខ្លួន អត់មានទេ បើអ្នកស្រុកទៅជួបដែលគាត់នៅហ្នឹងណា៎ ហើយមករកអីម៉េចមិនកាប់ដីដាំ

ដំណាំអី  មកបានស៊ី  គ្រែងអញនៅតែក្នុងព្រៃអញមានអី  ជួនណាជួបទៅបោះឲ្យ១០០ ចឹងទៅ  អត់មានអីទេ

រ៉ាស៊ីៈ  បោះលុយឲ្យ?

មីៈ  បោះឲ្យ  អញមានអី  អញដើរគ្រាន់តែ...

រ៉ាស៊ីៈ  អ្ហ៎ក?  ជំនាន់ណាគេចាយលុយ?

មីៈ  ដែលកាលដែលរត់ឥឡូវនេះ

កុសលៈ  ថ្មីៗហ្នឹង?

មីៈ  អឺ!  ពេលដែលជួបអន្លង់វែងជួបអីដែលអ្នកតាមនោះណ៎

កល្យាណៈ  អ្នកណាទៅជួបយាយ?

មីៈ  ចុះអ្នកមានកូនចៅនៅឯនោះ  ហើយដល់ទៅជួបគាត់  ចុះមករកអី  ទៅដល់ស្រុកហើយមិនខំធ្វើការរកស៊ី  មករកអី  ហើយថាអត់លុយជិះឡានណ៎លោកអ៊ំ  ហើយអញរកអី  អញមិនមែនអ្នករកលុយរកកាក់អីអញ  អ្ហ៎ក!  អញមាន១០០  បោះឲ្យ  អា១០០បាតហ្នឹងណ៎ ហើយទៅវិញខំកាប់ដីដាំដំណាំដាំអីស៊ីកុំដើររក  និយាយចឹងណ៎  យើងត្រូវតែកាប់  ត្រូវតែគាស់  ត្រូវតែដាំ  កុំដើររកគេ  កុំសុំគេ  គាត់កាចទេបើមានអីឲ្យគេរលីង  បើសិនជានេះបានធ្វើផ្ទះនៅហើយណ៎  បើគាត់ចេះសន្សំចេះទុកចេះដាក់  ប៉ុន្តែគាត់អត់ចេះសន្សំទេ ។

រ៉ាស៊ីៈ  ខស្សាប់ទៅជួបណាស់ចឹង?

មីៈ  បើជួបអ្នកគេទៅៗហ្នឹងគេថាជួបតាម៉ុកអត់ប្រយោជន៍ទេ  យ៉ាងច្រើនឲ្យ១០០បាតហ្នឹង ហើយបើជួបដូចអាទិត្យដូចអីគេអ្នករកស៊ីណ៎ គេដាំចម្ការគេដាំអីអាហ្នឹងបានឲ្យ២០០  អត់ចេះសន្សំ  អាវ១ខោ១  គាត់អត់ចេះប្រកាន់ខ្លួនឯណាបើគាត់ធ្វើដូចប្រជាជនអីចឹង  ហើយមិនដែលទៅនឹកឃើញថានេះទេ  ប៉ុន្តែឥឡូវហ្នឹងមិនដឹងអាម៉េចទៅ  អត់ដែល...  គ្រាន់តែកូនអស់ហ្នឹងមកម្សិលមិញហ្នឹងមកផ្ទះកាពូនហ្នឹងណ៎  មកយកកាពូនហ្នឹងទៅមើលតាម៉ុកណ៎  ទៅហ្នឹងវាឲ្យឃើញ  ហ្នឹងវានិយាយទេណ៎  ថាហ្នុំប្រហែលរោងនោះ  ប្រហែលរោងសាលាចាស់នោះ (គាត់ចង្អុលរោងនៅក្នុងវត្តដែលមានចម្ងាយប្រហែល៥០ម៉ែត្រពីកន្លែងអង្គុយ) ។

កល្យាណៈ  ឃើញគ្នាចម្ងាយហ្នឹង  អត់ចូលជិតទេ?

មីៈ  អត់ទេ  គ្រាន់តែឃើញចម្ងាយហ្នឹងហើយយើងមានទិញអីៗទៅអ្នកធ្វើបាយហ្នឹងណ៎  គេអ្នកយកទៅឲ្យ...ហើយដល់ហើយកាពូនវាចង់ទៅមើលទៅណ៎  ចង់ទៅមើល  បេះដូង៤-១០ ទៅ  ហើយយកអង្ករ

រ៉ាស៊ីៈ  ចិត្តអត់ដាច់ហ្ន៎  គ្រែងថាគាត់គាត់កាល់បងប្អូនចោលហើយអ្ហឺ?

មីៈ  ហ្នឹងហើយ!  ឲ្យកាពូនផ្ញើអង្ករឲ្យអញស៊ីផង

**កុសលៈ** ចឹងនៅទាក់ទង គេឲ្យទៅមើលទៅអីបានមែនទេ?

**មីៈ** អត់ទេ សួរវាតាំងពីមកថាគេឲ្យទៅមើលជិតដែរឬអី? វាថា ន៎! ប្រហែលកុដិលោកនោះ គ្រាន់តែឈរចឹងហើយអ្នកធ្វើបាយហ្នឹងគេយកទៅទុកទៅ ហើយដល់ហើយគេយកឲ្យគេប្រាប់ ថាកូននេះមកចង់ឃើញ កូននោះចឹងទៅ គេអត់ឲ្យទៅជួបបានមាត់បាននិយាយអីទេ ។

**កុសលៈ** សរសេរសំបុត្រឆ្លើយឆ្លងអីអត់បានទេ?

**មីៈ** អត់ទេ គ្រាន់តែឲ្យឃើញ ហើយអញថាចុះបើសិនយើងដាក់ឥវ៉ាន់ហ្នឹង យើងដាក់ទៅថាចង់ជួប ហើយធ្វើសំបុត្រទៅនឹងឥវ៉ាន់ហ្នឹងគេអត់តែម្តង រៀបយកគេឆែក ព្រោះដល់តែមានស្អីទៅគេឆែកហើយអស់បានគេយកទៅ គេខ្លាចយើងដាក់ឆ្លើយឆ្លងណា៎

**កុសលៈ** ដាក់អី?

**មីៈ** ខ្លាចយើងធ្វើបង្កប់ក្នុងចំណីហ្នឹងហើយឆ្លើយឆ្លងគ្នាហ្នឹងណា៎ ទាក់ទង អាហ្នឹងវាថាអីចឹង ខ្ញុំសួរវា វាថាអីចឹង គ្រាន់តែទៅដល់អ្នកយាមគេថាអត់អីទេចាំខ្ញុំយកទៅឲ្យអ្នកធ្វើបាយ ហើយដល់អ្នកធ្វើបាយគេបញ្ជូនទៅគេប្រាប់ថាមានកូនចៅ...ហ្នឹងគេប្រាប់ គេមកបកប្រែប្រាប់យើងវិញណា៎ ឥវ៉ាន់ខ្ញុំបានយកដល់នោះហើយ ហើយប្រាប់គាត់ហើយ ហើយវាមើលទៅឃើញអើតនៅក្នុងហ្នឹងណា៎ អើតនៅខាងមុខហ្នឹង ហើយគេថាចាស់ឬក្មេងមើលពីចម្ងាយហ្នឹងឬមិនមែនហ្នឹង ពុតែគេសួរណា៎ វាថាហ្នឹងហើយមើលពីចម្ងាយទៅ ប៉ុន្តែមើលវាអត់ឃើញជិត ហើយបើថាចំណាស់ខ្ញុំអីមិនបាច់ទៅមើលទេ មើលអត់ឃើញទេ ហើយកាពូនហ្នឹងវាអត់ចង់ទៅមើលវាមើលអត់ឃើញ ទៅមើលឆ្ងាយចឹង មានតែអាម៉ុលអីហ្នឹង ភ្នែកគេភ្លឺគេមើលឃើញទៅណា៎ ឃើញប៉ុន្តែអត់បាននិយាយរកណា៎ គ្រាន់តែយកទៅហុចឲ្យអ្នកធ្វើបាយទៅ ហើយមើលទៅឃើញអង្គុយកន្លែងនៅហ្នឹងណា៎ អត់បានទៅសួរទៅមាត់អីទេ ។

**កល្យាណៈ** គាត់ទៅមើលបានប៉ុន្មានដងហើយយាយ?

**មីៈ** កាពូន?

**កល្យាណៈ** ចា៎!

**មីៈ** ទើបនឹងទៅហ្នឹង

**កល្យាណៈ** ទើបនឹងម្តងហ្នឹងទេ?

**មីៈ** អឺ!

**កល្យាណៈ** ចុះមុនៗអត់ដែលទៅទេ?

**មីៈ** មុនពួកកាសែតដឹកទៅ ដឹកទៅហើយដែលថាថតអញអីហ្នឹង ថាយកទៅគេឲ្យចូលទៅជួបផ្ទាល់

**កល្យាណៈ** រួចបានជួបឬអត់?

**មី:** បានអីវា ហើយដល់ហើយវាមកពីនោះមកវាឃើញផ្ទះសុំថតមួយ អញក៏ឲ្យថតទៅ ប៉ុន្តែអញវាអត់យកទៅបិទជាមួយទៅណា៎ រួចសួរថាបងប្អូនត្រូវម៉េច អញថាអត់ទេគ្រាន់តែនៅស្រុកនឹងគ្នាទេ ហើយបិទតែកាពូនគេបិទមុខវាធ្មេញ២ស្មេញចឹងទៅ ហើយដល់ហើយអញថាយកអញទៅថតដាក់រូបអញមិនទៅឲ្យទេ ។

**វ៉ាស៊ី:** ហើយចរិតបងប្អូនហ្នឹងដូចគ្នាទាំងអស់ចឹងអ្ហ?

**មី:** ដូចគ្នាទាំងអស់

**វ៉ាស៊ី:** អ្នកណាចិត្តល្អជាងគេមើលទៅបងប្អូនទាំងអស់ហ្នឹង?

**មី:** ទេ វាពិបាកណាស់វ៉ី ពួកហ្នឹងវាគ្រាន់តែអឺបេះ រកថាមិនឃើញ រកស៊ីវាខំអត់ដឹងផាប់ដឹងរស់ ហើយកាពូនហ្នឹងត្រូវភ្លូរៗ រាស់ៗ កាប់ដីកាប់ រកស៊ីចឹងណា៎ ប៉ុន្តែបើមានបុណ្យមានទានអីទៅធ្វើប្រឡូកបុណ្យប៉ុន្មានថ្ងៃ មួយអាទិត្យម្ដងយកបាយមកដាក់ទៅ ប៉ុន្តែគ្រាន់តែឲ្យសាហូសាហាវអីអត់ទេ ធ្វើតែបុណ្យដែរទេ ដូចនែ៎របងហ្នឹង (របងវត្តត្រពាំងធំ) អាប្អូនមកហ្នឹងថាកាប់ចម្ការទេនៅហ្នឹង កូនៗហ្នឹងណា៎ មកចូលបានម្នាក់១០រៀល ១០បាតហ្នឹងណា៎ ថាខ្ញុំ ឥឡូវរកអីគ្មានទេ ធ្វើស្រែមុខខ្មៅព្រីកៗ ហើយដៃណាអាក្រក់ណាស់ កាប់ចម្ការដាំដំឡូង ដាំអីហ្នឹងណា៎ ដាំចេក នៅគេហៅអាអី អន្ទង់វែងនោះណា៎ ហើយមកហ្នឹងសន្សំតាំងពីដូង តាំងពីកូនស្វាយទៅដាំ ដើររកហើយដាក់រ៉ឺម៉កទៅ ។

**វ៉ាស៊ី:** ហ្នឹងបងប្អូនគាត់ហ្នឹងអ្ហូស? បងប្អូនស្រីៗដែលនៅរស់ហ្នឹងអ្ហូស?

**មី:** កូនតាម៉ុកនេះ

**វ៉ាស៊ី:** កូនអ្ហូស?

**មី:** អឺ!

**កល្យាណ:** ឥឡូវកូនគាត់នៅរស់ប៉ុន្មានយាយ?

**កុសល:** កូននៅ មាស មុត មួយ

**មី:** អឺ! មាស មុត ហ្នឹងកូនប្រសាទេ ប្ដីអា ខុម ណា៎

**កល្យាណ:** ហើយ ខុម ហ្នឹងស្លាប់ហើយ?

**មី:** ខុម ស្លាប់ហើយ...ដើរវៃវិហារវៃបល្ល័ង្កអីចោលអស់ ហើយទៅវៃវត្តស្រះធំឆ្លតបណ្ដោយ

**កល្យាណ:** ជំនាន់អាពតហ្នឹង?

**មី:** អឺ! វៃព្រះអង្គវត្តស្រះធំ កាលនេះបញ្ឈរទៅធ្លាក់ផាប់២ វិហារនេះវៃព្រះពុទ្ធរូបទម្លាក់ក្នុងស្រះនេះ ឯងគេឲ្យវែកភក់ វែកតាមនេះទៅឃើញស្ពឹងៗ ផាប់ឡើងហើម ហើយដល់ទៅវៃវត្តស្រះធំ គ្រាន់តែហើយខោមូរជើងហ្នឹងក្លាហានអង់អាច អាវលែងពាក់ ខោលែងស្លៀកឆ្លតទៅ មី ខុម ប្រពន្ធតាមុតហ្នឹងណា៎ ។

រ៉ាស៊ីៈ អ្នកវៃវិហារវៃអីដែរ?

មីៈ វៃព្រះអង្គ វៃព្រះពុទ្ធរូប វៃវិហារ ហើយឆ្លតផាប់ទៅ ហើយឥឡូវយកប្រពន្ធក្រោយ មិនដឹងឈ្មោះអី អញមិនដែលឃើញមុខផង ទើបឃើញម្តងវាមកលេងផ្ទះកាពូន មកចូលរបស់លោកមួយប្រឡោះ ។

កុសលៈ ចឹងលោកយាយមានរូបតាម៉ុកកាលនៅក្មេងអី រូបគាត់ មានសល់រូបថតអីទេ?

មីៈ អត់ទេ អត់ដែលបានឃើញមុខ

កុសលៈ រូបកាលគាត់ក្មេងកូនង៉ាអីណ៎

មីៈ អត់ទេ នៅភូមិជិតគ្នាដែរប៉ុន្តែមិនដែលទៅថតអី ចាស់ៗពីដើមមានអ្នកណាដែលថតតែម្តាយអារ៉េត (ម៉ុក ម៉ារ៉េត) ហ្នឹងផាប់ទៅអត់រូបថត១ទុកឲ្យកូនមើលផង មានដែលថតដែលអី ។

រ៉ាស៊ីៈ មិនស្រួលអត់ស្គាល់មុខម្តាយផងតារ៉េត

មីៈ អត់ទេ ហៅខ្ញុំតែម៉ែហ្នឹង ឲ្យតែមកម៉ែៗ ឥឡូវក៏នៅតែម៉ែ អត់ដឹងម៉ែហ្នឹងអាម៉េចផង

កល្យាណៈ តាម៉ុកបាក់ជើងឆ្នាំណាយាយដឹងទេ?

មីៈ អត់ដឹងទេវើយ

កល្យាណៈ ចុះកាលដែលគាត់មកប្រជុំនៅឯនេះពីជំនាន់អាពតគាត់មិនទាន់បាក់ជើងទេអ្ហេស?

មីៈ អត់ទេ បាក់ហ្នឹងរៀបបែកហើយហ្នឹង

កល្យាណៈ រៀបបែកវៀតណាមចូលហ្នឹង?

មីៈ អឺ! ដែលថាបាក់ហ្នឹងអាគ្រោះបើកទៅ ហើយគាត់ទៅបញ្ជា វាដាច់អាច្រវាក់ហ្នឹងទេតើ

កុសលៈ វាត់ប៉ះជើង?

មីៈ អឺ! វាត់បាក់ ។

រ៉ាស៊ីៈ មិនមែនត្រូវគ្រាប់ទេហ្ន៎?

មីៈ មិនមែនទេ អាច្រវាក់ហ្នឹងដាច់ប៉ះ ខ្ញុំឮអ្នកគេទៅគេថាណ៎

កល្យាណៈ ចឹងពេលដែលរត់ទៅជួបគាត់នៅភ្នំហ្នឹងគាត់បាក់ជើងហើយ?

មីៈ នៅទេ កាលដែលយើងរត់ទៅជើងគាត់នៅទាំង២ ហើយដល់គាត់ទៅធ្វើចម្ការធ្វើអីនៅស្រុកថៃព្រំប្រទល់ គាត់បញ្ជាអាគ្រោះឲ្យកិន ហើយដល់វាដាច់ច្រវាក់ហ្នឹងទៅពារដាច់ជើងទៅណ៎ ។

រ៉ាស៊ីៈ ស្រុកថៃឯណោះទេចឹង?

មីៈ អើ! ព្រំប្រទល់គាត់នៅឯណោះ តាម៉ុកហ្នឹងនៅព្រំប្រទល់

រ៉ាស៊ីៈ ហើយប្រពន្ធគាត់ទៅស្លាប់នៅថៃដែរ?

មី៖ ស្លាប់នៅព្រំប្រទល់

កល្យាណៈ ម៉េចដឹង? យាយម៉េចដឹងថាប្រពន្ធគាត់ស្លាប់នៅព្រំប្រទល់?

មី៖ ចុះកូនអស់ហ្នឹងមកវានិយាយ កូនមកវាចូលទៅផ្ទះកាពូននេះ ជិះរ៉ឺម៉កមក

កុសលៈ ចុះឥឡូវតាម៉ុកហ្នឹងត្រូវគេឃុំនៅភ្នំពេញអ្ហែស?

មី៖ នៅគុកទួលស្លែង

កុសលៈ ដាក់នៅគុកទួលស្លែង

មី៖ អឺ! គេថានៅទួលស្លែង សួរមីកាពូនហ្នឹងណា៎ ថាមិនមែនអាគុកប៉ុស្តិ៍ពីដើមទេ

កុសលៈ មិនមែនតេ-៣ទេ?

មី៖ អឺ! នៅខាងលិចអីចេះ ហើយអញសួរត្រង់ណាអញមិនដែលឃើញអាគុកអីនឹងគេផង ពុកែថាគុកទួលស្លែងៗហ្នឹងណា៎ ហើយវាថានៅឯណោះ អាគុកនេះនៅអីចេះ ។

កុសលៈ លោកយាយស្គាល់គុកទួលស្លែងដែរតើអ្ហី?

មី៖ ស្គាលកាលទៅរកឆ្អឹងបងដែលខាងកប៉ាល់ហោះហ្នឹង ពុកេថាងាប់នៅឯហ្នឹង អញទៅរកមើលឆ្អឹង ។

កុសលៈ លោកយាយទៅរកដែរអ្ហែស?

មី៖ រកយកមកធ្វើបុណ្យណា៎

កល្យាណៈ អ្ហ៎! រកឃើញអ្ហ៎សយាយ?

មី៖ មិនដឹងឆ្អឹងនរណាបើច្រើនម៉្លឹងៗ

កល្យាណៈ ចឹងរកអត់ឃើញទេ?

មី៖ អឺ! អាណិតបងខ្លោចចិត្ត

រ៉ាស៊ីៈ ហើយមានឃើញរូបថតអីនៅឯហ្នុងទេ?

មី៖ វាអត់ហ្នឹងណា៎ ទៅរកកាលបែកហើយ គេថាចង់ឃើញឆ្អឹងកូនចៅទៅមើលឯហ្នឹងណា៎ ហើយដល់ទៅរកទៅវាមិនដឹងអាណាជាអាណី

កុសលៈ ចឹងលោកយាយឃើញឆ្អឹងច្រើនទេនៅឯហ្នុង?

មី៖ ឃើញ ប៉ុន្តែដឹងតែឆ្អឹងអីចឹង មិនដឹងអាណារបស់គេ អាណារបស់យើង

កុសលៈ ចុះគ្រួសារលោកយាយអស់ប៉ុន្មាននាក់ដែរជំនាន់ ប៉ុលពត?

មី៖ អស់ប្អូនអា រ៉េត ហ្នឹង២ណា៎ ហើយនិងបងមូលហ្នឹងខាងកប៉ាល់ហោះហ្នឹង ស្លាប់បាត់កូននៅរញោវ

កុសលៈ អីចឹងលោកយាយជឿថាមេខ្មែរក្រហមសម្លាប់មនុស្សទេ?

មី៖ បើមិនសម្លាប់អាម៉េចបើងាប់ហិនហោចអស់ទៅហើយហ្នឹង

កុសលៈ លោកយាយខឹងតាម៉ុកទេ?

មីៈ និយាយមិនខឹងអាម៉េច ប៉ុន្តែឥឡូវចាស់ទៅធ្វើធម៌ធ្វើអាថ៌ទៅចេះតែនៅស្ងៀម កាលពីដើម ន៏ ឲ្យតែឃើញមុខមកអញកាប់ចោល

រ៉ាស៊ីៈ ឃើញមុខមកសម្លាប់ចោលតែម្តង?

មីៈ ចុះបើបងមូលហ្នឹងគាត់រៀននិស្សិតស្រុកបារាំងណា៎ហើយដល់មកវិញនៅធ្វើខាងពោធិចិនតុង ហ្នឹងប្រធានទៀតណា៎

រ៉ាស៊ីៈ ហើយម៉េចបានជាមកវិញអីចឹង ក្រែងទៅបារាំងហើយ? អ្នកណាទៅហៅមកបុក៏ម៉េច?

មីៈ គាត់មកនៅធ្វើការឯហ្នឹង ដល់ថាកើតខ្មែរក្រហមហើយគាត់ឡើងកប៉ាល់ហោះទៅវិញណា៎ រួចឡើងទៅគេបាញ់ទម្លាក់ទៅណា៎ បាញ់ទម្លាក់ជាមួយកូនតាក្បាត់ អាគ្មិន អាគួនហ្នឹង សុទ្ធតែនិស្សិតស្រុកបារាំង ទៅរៀននៅស្រុកបារាំងណា៎ ។

កុសលៈ លោកយាយខឹងតាម៉ុកថាកាលមុនឲ្យតែមកហ្នឹង...

មីៈ យាយព្រួញឈ្មោះមិនបាន គ្រាន់តែព្រួញឈ្មោះអញស្អប់ ។

កុសលៈ ដល់ពេលឥឡូវហាក់ដូចជាថា...

មីៈ វាធម្មតា ទឹកពិចារណាតាមផ្លូវធម៌ទៅ

កុសលៈ តាមផ្លូវធម៌យ៉ាងម៉េចដែរទៅ?

មីៈ ផ្លូវធម៌បើអ្នកណាធ្វើអីបានហ្នឹង ធ្វើអំពើអីបានអំពើហ្នឹង

កុសលៈ អីចឹងលោកយាយគិតថាទុកឲ្យតាម៉ុកទទួល...បើសិនគាត់បានធ្វើអំពើហ្នឹងគាត់ទទួលកម្ម របស់គាត់ទៅ?

មីៈ គាត់ទទួលផលតាមហ្នឹងទៅ ព្រោះបើយើងធ្វើល្អវាជួបល្អ បើយើងធ្វើម៉េចវាបានអីចឹង ឧបមាបើគាត់ធ្វើមកចិត្តល្អ មានធម៌សប្បុរសទៅលើប្រជាជនទេក៏ទេវតាលោកជួយបាន ចម្រើនអីចឹងទៅដែរ ហើយបើយើងធ្វើកាប់សម្លាប់អីចឹងទៅវាតាមផលហ្នឹងណាក្មួយ មិនមែន...សងសឹកគ្នាទេណា៎ មិនមែនទេ យើងទៅសម្លាប់គេ គេសម្លាប់យើង គេធ្វើបាប យើង យើងធ្វើបាបគេ អារឿងវាលោកគេក៏អីចឹងដែរ មានការស៊ីសង ហើយយើងចង់ឲ្យ សុខឲ្យស្រួលអាម៉េចបើប្រជាជនរាប់លានងាប់អស់ ហើយដល់ទៅអាអ្នកអត់ចេះអក្សរយក មកធ្វើចៅហ្វាយស្រុក អាអ្នកនិស្សិតស្រុកបារាំងសម្លាប់ចោលអស់ ហើយអ្នូតឯងចង់ កាន់កាប់ប្រទេស ព្រះពុទ្ធរូបវ៉ៃចោល លោកផ្សឹក ហើយបានសោយផលប៉ុន្មាន ៣ឆ្នាំមិន បានផង ហើយ ហ៊ុន សែន ដែលគាត់បានសោយផលហ្នឹងណា៎ ព្រោះគ្រាន់តែបែកហើយ គាត់កសាង ព្រះពុទ្ធរូបឲ្យធ្វើ វត្តឲ្យធ្វើវិញ កូនក្មេងឲ្យរៀនវិញ តម្រិះវិជ្ជា ហើយចង់ធ្វើ

បាបគាត់មិនខាយទេ ទេវតាទ្រទ្រង់គាត់ហើយ ធ្វើល្អបានល្អក្អួយអ្វើយ ទោះធ្វើអាក្រក់វា ឈ្នះក្រឡាប់ផ្កាប់ផ្ងារ ដូចនាំគ្នាវ៉ៃព្រះហើយ ដាវលំពែងទៅវ៉ៃព្រះអង្គ

កុសលៈ អ៊ីចឹងក្នុងចិត្តលោកយាយ អ៊ីដែលតាម៉ុកធ្វើកន្លងមកគឺខុស?

មីៈ ខុស! មិនខុសអាម៉េចបើងាប់ហិនហោចមួយផ្ទះៗលើងទៅហើយហ្នឹង ហើយបើធ្វើដូចយើងឥឡូវសូម្បីតែចោរក៏គ្រាន់តែណែនាំឲ្យចេះឲ្យដឹងឲ្យយល់ដែរ ហើយបើកាលហ្នឹងងាប់ហិនវេទនាពេញហើយ បើងាប់អស់រលីងហើយ ប្អូនអា រ៉េត នេះងាប់២ស្មាដៃហ្នឹង

វ៉ាស៊ីៈ ចឹងលោកយាយយល់ថាម៉េចដែរដែលរបបពាន់ឆ្នាំ៨ខែដែលកាន់កាប់ដោយ ប៉ុល ពត ហើយក្នុងនោះមានតាម៉ុកចូលរួមដែរនោះ? លោកយាយយល់ថារបបហ្នឹងជារបបយ៉ាងម៉េចទៅ?

មីៈ របបហ្នឹងបើតាមខ្ញុំយល់ណា៎ មនុស្សដែលរំលាយព្រះពុទ្ធសាសនាមិនដែលបានសោយផលទេ ក្អួយឯងឃើញគេលេងឲ្យមើលទេ? អ្នកណាធ្វើល្អបានផលល្អ ហើយអ្នកណាធ្វើអាក្រក់ឃើញទេ ពាន់ឆ្នាំបង្អត់ប្រជាជនចង់ងាប់ ផ្ទះយាយមិនមែនតូចទេណា៎ចៅ រុះយកទៅធ្វើទុំ (លោកយាយចង្អុលទៅរោងមួយនៅក្នុងវត្ត) ព្រោះបងប្អូននៅភ្នំពេញទាំងអស់ គេរុះហើយគេលើកដៃអ៊ីចឹងនែ៎ ថាអត់មានលូតវែងខ្លីទេ កាត់ត្រឹម អត់មានអ្នកមានអ្នកក្រទេ ហើយឪពុកខ្ញុំគាត់អត់ហូបបាយបង្អត់បាយទាល់តែស្លាប់ ។

កុសលៈ ចុះបើគេឲ្យលោកយាយទៅជួបតាម៉ុក លោកយាយចង់សួរតាម៉ុកថាម៉េចខ្លះ?

មីៈ សួរគាត់ឆ្លើយចឹង គេសួរដែរតើ

កុសលៈ ទេ បើឧបមាថាគេឲ្យលោកយាយជួប លោកយាយសួរគាត់ថាម៉េចខ្លះ?

មីៈ សួរដែរ បើជួបសួរដែរ

កុសលៈ សួរថាម៉េចទៅ?

មីៈ ថាចុះបើមហាលោភឆ្លោះហើយម៉េចបានជាមកនៅឯនេះវិញ សួរអ៊ីចឹងព្រោះថាកាលហ្នឹងសុទ្ធតែមហាលោភមហាឆ្លោះ អត់មានធ្វើឲ្យ... ចុះមិនឃើញ ហ៊ុន សែន ថាតាម៉ុកខ្ពស់ទៅមានអី មានតែមេឃហើយនិងមួកអ្ហួស?

កល្យាណៈ លើម៉ុកមានមួក លើមួកមានមេឃ

មីៈ អើ! មិនបាច់អ្នកណានិយាយទេតាម៉ុក លើម៉ុកមានមួក ហួសពីមួកមានតែមេឃទេ ហើយដល់គេនិយាយល្អគាត់ស្តាប់អត់បានទេណា៎ បើសិនជាស្តាប់គ្នាបានមិនមែនវេទនាយូរអ៊ីចឹងទេណា៎ ប៉ុន្តែប្រឆាំងយកឈ្នះ

កុសលៈ គេប្រាប់គាត់ថាម៉េចទៅគាត់ចង់យកឈ្នះហ្នឹង?

មី: គាត់ស្មានតែវ៉ៃបែកភ្នំពេញហ្នឹងគាត់បានធ្វើស្ដេចណ៎ា មិនដឹងថា...យើងនិយាយធ្វើស្អី មនុស្សដែលហ៊ានច្បាំងគេច្បាំងយកធ្វើម្ចាស់ប្រទេសណ៎ា គេមិនមែនច្បាំងធ្វើកូនចៅទេណ៎ា ហើយដល់ធ្វើវាមិនកើតពីព្រោះ ហ៊ុន សែន គាត់មាននិស្ស័យណ៎ា គាត់ធ្វើល្អ គាត់កាន់ព្រះពុទ្ធសាសនា មានវត្តមានលោក ម៉្លោះហើយគាត់ត្រូវទទួលផលបានយូរ ប៉ុន្តែនិយាយរួមទៅដូចសម្ដេចអីចឹង គាត់ថ្វាយតែបង្គំ គាត់ដែលទៅសម្លាប់អីអ្នកណា ហើយឃើញទេ ទោះជាយ៉ាងណាក៏សម្ដេចនៅតែប៉ុណ្ណឹង ហើឥឡូវហ្នឹងណ៎ាខ្ញុំនិយាយប្រាប់ក្មួយឯងឲ្យត្រង់ អ្នកទាំងពីរណ៎ា មួយម្ដាយ មួយឪពុក អត់មានប្រមាថទេ ខ្ញុំនិយាយស្មោះត្រង់ យកទៅស្ទាវឯណាយកទៅ ។

រ៉ាស៊ី: អ្នកណាម្ដាយ អ្នកណាឪពុក?

មី: ដូចថា ហ៊ុន សែន ម្ដាយ សម្ដេចឪពុក ព្រោះ ហ៊ុន សែន គាត់ជួយរំដោះយើងរួចមកពីរបបហ្នឹង

កុសលៈ ចុះតាម៉ុកជាអីចឹង?

មី: តាម៉ុកជាខ្មាំង អីបើមិនខ្មាំងបើប្រជាជនងាប់អស់ហើយ ដល់ចូលមកហើយបើសិនជាគេមិនយកបានគាត់មក? នៅតែបន្តចឹង...

រ៉ាស៊ី: អីចឹងជីវិតរបស់តាម៉ុកលោកយាយជឿថាទុកឲ្យផលកម្មជាអ្នកកាត់ទោសគាត់អ្ហេស?

មី: អាហ្នឹងវាតាមផលរបស់គាត់ធ្វើហ្នឹង មិនព្យាយថាទេ? បើគាត់ធ្វើល្អជាមួយនឹងគេ គេក៏ល្អជាមួយគាត់វិញទៅ ហើយបើអំពើគាត់ធ្វើអាក្រក់ទទួលផលអាក្រក់វិញទៅ ហ្នឹងនិយាយធម៌មានតែប៉ុណ្ណឹង ។

កល្យាណៈ មានកូនចៅតាម៉ុកដែលទៅជួបតាម៉ុកនៅភ្នំពេញទេ?

មី: អត់ដែលបានជួបទេ ហ្នឹងដែលសួរអ្នកមកៗគេសួរណ៎ា ថាអត់បានជួបទេ បានតែនំទៅប្រហែលកុដិលោកនោះ ហើយឈរឯហ្នឹង ហើយយកឥវ៉ាន់ទៅឲ្យហ្នឹង

កល្យាណៈ អត់បាននិយាយឆ្លើយឆ្លង?

មី: អត់ទេ! ថាអត់ដែលបានឆ្លើយគ្នាអី១ម៉ាត់ទេ កាពូនហ្នឹងទៅម្ដងដែរ អ្នកកាសែតគេថាគេយកទៅឲ្យជួប បានថតចុះកាសែតហ្នឹងណ៎ា ចាញ់បោកគេ ថាទៅគ្រាន់តែទៅដល់កន្លែងយាមគេអត់ទាំងឲ្យទៅជិតផង អញថាចុះអ្នកកាសែតហ្នឹងឲ្យចូលដែរ? អត់ ។

រ៉ាស៊ី: ចុះបើសិនជាតាម៉ុកត្រូវបានកាត់ទោសដោយតុលាការណាមួយតើយាយគិតយ៉ាងម៉េចទៅ?

មី: គិតថាម៉េចតាមយើងធ្វើ មិនព្យាយនិយាយទេអ្ហេស?

រ៉ាស៊ី: អត់មានស្ដាយស្រណោះថាត្រូវជាប់សាច់ញាតិបងប្អូនអីទេ?

មី: តែយើងធ្វើមកល្អវាជួបនឹងគេទុកឲ្យល្អទៅ បើយើងមានអំពើអកុសល សម្លាប់គេ ធ្វើបាបគេ យើងត្រូវតែសងគេវិញណាំ យាយថាអីចឹងហើយ យាយមិនថា ពីព្រោះតាមយើងធ្វើ ។

រ៉ាស៊ី: ហើយចុះលោកយាយមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលដែលយើងមានការកាត់ទោស តាម៉ុកអីចឹងណាំ មេខ្មែរក្រហមដូចជាតាម៉ុកដូចជាអី ហើយជាពិសេសជាប់សាច់ញាតិអី ជាមួយលោកយាយអីចឹងអារម្មណ៍យ៉ាងម៉េចដែរ? អារម្មណ៍របស់លោកយាយផ្ទាល់ តែម្តងណាំតើមានស្តាយស្រណោះឬក៏...

មី: អត់ទេ អត់មានស្តាយស្រណោះអីទេ នឹកឃើញអីចេះវាចេះតែអារម្មណ៍អីចឹង បងខ្ញុំកាល អាពតវាសម្លាប់នៅពោធិចិនតុង តាម៉ុកធ្វើការកាលហ្នឹងម៉េចក៏មិនជួយបាន អានេះវាគិត តាមហ្នឹងទៅណាំ ។

រ៉ាស៊ី: ចឹងលោកយាយអត់មានស្តាយស្រណោះអីគាត់ទេណាស?

មី: ស្តាយអីបើគេធ្វើម៉េចបានអីចឹង មិនឮយាយថាទេ? យាយខំតែធ្វើបុណ្យធ្វើទានធ្វើសីល ទៅ ហើយបើគាត់ធ្វើមកល្អ គាត់សង្គ្រោះគេ ទុកជីវិតគេ គាត់ត្រូវបានសេចក្តីសុខទៅ ហើយបើគាត់សម្លាប់គេ គាត់ទទួលផលហ្នឹងវិញទៅ អាហ្នឹងវាអីចឹង ។

កល្យាណ: ចុះបើឧបមាថាបើគាត់រួចពីគុកមកវិញហើយគាត់ចង់មករស់នៅស្រុកភូមិជាមួយចឹងលោក យាយគិតម៉េចដែរ?

មី: អាហ្នឹងនៅលើរដ្ឋអំណាច បើរដ្ឋអំណាចគេថាឲ្យនៅក៏នៅទៅ

កល្យាណ: តែអាចថារដ្ឋអំណាចគេឲ្យនៅ តែអ្នកភូមិថាស្អប់គាត់មិនឲ្យនៅមិនឲ្យអី លោកយាយមាន ស្អប់គាត់អីចឹងទេ បើគាត់មកនៅលោកយាយឲ្យគាត់នៅក្នុងភូមិស្រុកទេ?

មី: ខ្ញុំមិនសងសឹកទេ ឥឡូវខ្ញុំធ្វើធម៌ធ្វើអាចីទៅហើយ ក្រែងក្មេងៗហ្នឹងថាមិនត្រូវទេ ក្រែងវា មាននូវការឈឺចាប់ក៏មិនដឹង ហើយបើដូចខ្ញុំ ខ្ញុំថាអ្នកណាធ្វើអីបានហ្នឹង បើគេឲ្យខ្ញុំសម្លាប់ក៏ខ្ញុំ មិនសម្លាប់ដែរ មិនថាតែតាម៉ុកទេ គ្រាន់តែមាន់ទាពាល់ថ្ងៃយាយលែងសម្លាប់ទៅហើយ យាយកាលទៅវត្តសំបូរយាយជី៣០០ យាយទៅធ្វើធម៌១០ថ្ងៃទើបនឹងមកលីចបថ្ងៃហ្នឹងទេ ។

រ៉ាស៊ី: ជជែកវែកញែកជាមួយលោកយាយក្រែលដែរហើយមិនទាន់ស្គាល់ឈ្មោះលោកយាយផង លោកយាយឈ្មោះអីលោកយាយ?

មី: ឈ្មោះ គល់ មី

រ៉ាស៊ី: អាយុប៉ុន្មានហើយ

មី: ចិតគត់ ៧១ឆ្នាំ

រ៉ាស៊ី: ស្រុកកំណើតលោកយាយនៅឯហ្នឹងរហូតតែម្តងឆ្នាំតាំងពីណាពីណើមក?

មី: នៅភូមិហ្នឹងតែម្តង។

ចប់

# បទសម្ភាសន៍ជាមួយលោកអ៊ំ វ៉ែត ខេង ប្រធានភូមិត្រពាំងធំ
## ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០០)

ខេងៈ ដល់សួរថាអីចឹង បើថានិយាយទៅក៏វាខុស ថាពាក្យទៅក៏វាខុស ប្រហែល បួសនេនទេ មិនទាន់បួសភិក្ខុទេណា៎ ខ្ទង់១៧-១៨ ហ្នឹងសុទ្ធតែអត់ពិតចឹងបានជាមិនចង់និយាយខ្ញុំណា៎ អាហ្នឹងបើតាមខ្ញុំដឹងណា៎ ឲ្យថាអ្នូរឿងគាត់បួសឆ្នាំនេះទៅទល់ឆ្នាំនេះបួសនេន ហើយគ្រាន់តែដឹងថាបួសនេនហ្នឹងហើយរៀនសូត្រជាមួយគ្នានៅវត្តនេះ(វត្តត្រពាំងធំ) ១វស្សាចឹងទៅ បែកផ្លូវគេក៏ទៅខ្ញុំក៏ទៅ គេទៅនៅភ្នំពេញទៅ គាត់ឪពុកម្តាយគាត់...

កុសលៈ ចឹងអ៊ំនៅជាមួយគាត់១វស្សាដែរ?

ខេងៈ នៅ រៀននៅវត្តនេះ១វស្សា

ចុះកាលពីក្មេងដែលរៀន ក ខ ទៅ រៀន...

ខេងៈ ក ខ គ ឃ ង ជាន់ហ្នឹងរៀនតែក្តារគនៅលើកុដិទេ រៀនជាមួយលោក គ្មានសាលាគ្មានអីទេ អត់ទេ រៀន នមោ ពីដើម នមោ ក ខ ហ្នឹងណា៎ៗ ហើយម៉្លោះហើយគាត់ហ្នឹងអីចេះរឿងតាម៉ុកហ្នឹង តាម៉ុកបើតាមខ្ញុំគិតទៅគាត់ហ្នឹងរៀននៅភ្នំពេញប្រឡងជាប់សាលាបាលីរងប៉ុន្តែមិនដឹងឆ្នាំប៉ុន្មានទៀត អត់បានទេណា៎ គ្រាន់តែដូនជាយោបល់ រៀនជាប់សាលាបាលីរងនៅបាន មើល២ឆ្នាំឬ៣ឆ្នាំ មកវិញមកផ្ទះនេះ...ដល់សឹកទៅវិញមកនៅជាមួយគ្នានេះបាន១ប្រាំងដែរ សឹកគាត់ថាអ្នូអញសឹកហើយ

វ៉ាស៊ីៈ ហ្នឹងសឹកពីភ្នំពេញមកវិញតើអ្វី?

ខេងៈ សឹកមកសឹកឯនេះ ដល់ហើយគេថាសឹកហើយ ខ្ញុំថាបើសឹកសឹកទៅ ដល់សឹកទៅគាត់មានប្រពន្ធនៅភូមិប្រកាបនេះត្រូវជាបងប្អូនគាត់ដែរណា៎ នៅភូមិប្រកាបហ្នឹងបងប្អូនខាងម្តាយយាយទឹមហ្នឹង ដល់តែទាក់ទងនិយាយហើយអីហើយការទៅៗ ហើយនិយាយហ្នឹងកាលសឹកមកវិញហ្នឹងក៏និយាយមិនសូវត្រូវជាមួយគេដែរទេ

អ៊ីចឹងពេលសឹកហ្នឹងគាត់បានសញ្ញាប័ត្រសាលាបាលីរង?

ខេងៈ បានសញ្ញាប័ត្រសាលាបាលីរងប្រឡងចូលសាលាបាលីជាន់ខ្ពស់ធ្លាក់ណា៎ ខ្ញុំក៏ធ្លាក់គេក៏ធ្លាក់អញថានែ៎ អ្នូសអញធ្លាក់ហើយអញគិតសឹក គាត់ឯងធ្លាក់ៗ បើជាប់ៗដូចតែគ្នាហ្នឹងបើគាត់ឯងធ្លាក់អញធ្លាក់ដែរ កាលសាលាបាលីរងជាប់ៗដូចគ្នា បើអីចឹងយើង គាត់ឯងទៅខាងភ្នំពេញប្រឡងធ្លាក់អញអត់ចូលទៅ បបួលទៅធ្វើកុដិនៅភ្នំពេញមួយអត់ប្រឡងអត់អីទេឈប់ហើយ ខ្ញុំថាអីចឹងណា៎ អ្នូសទឹងណាស់ប្រឡងធ្លាក់ សឹកហើយ សឹកទៅ ដល់សឹកទៅមិនសូវនៅផ្ទះទេ ការប្រពន្ធហើយហ្នឹងនៅមួយរយៈតូចទេ ថា១ឆ្នាំទៅ២ឆ្នាំចុះ

ប៉ុន្តែនៅហ្នឹង មិនមែននៅផ្ទះយើងធម្មតាទេ ហើយបើនិយាយស្ដីមានបុណ្យមានទានអីមានមាគាត់១ នោះឈ្មោះតានាក់ តែនិយាយទៅវាមិនត្រូវគ្នាទេ វាចេះព្រះពុទ្ធសាសនាដូចគ្នាដែរ និយាយទៅវាចេះតែទ្រង់តែហៅថានយោបាយប្រឆាំងណ៎ មិនសូវត្រូវគ្នាទេ

ម៉េចចឹងអ៊ំ?

**ខេខ:** វាដូចជាបែបខូចខួរក្បាលម៉េចទៅ ដល់មែនទែនទៅនិយាយចូលគេយូរៗទៅគិតតែរឿងជាតិរឿងអីទៅវិញទៅ ហើយកាលជាន់នោះមានសំបូរផ្នែកនយោបាយ? អត់ទេ ហើយចេះតែនាំគ្នាទៅ ឲ្យតែឃើញឈ្មោះជឿណ៎ គេហៅអាចារ្យជឿនទៅឯណាចូលហើយ ជជែកគ្នាចឹង ផាប់ហើយរ៉ិរកទីបំផុតមិនឃើញទេ អានោះថាអ៊ីចឹង ជជែកយកតែឈ្នះដូចគ្នា គ្រាន់តែនិយាយគ្នា